ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

# ទស្សនាវដ្ដី លេខ ៦

# គ្រូបង្រៀន



ខែ មេសា ឧសភា មិថុនា ១៩៩៧

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

# វិចារណកថា

ក្នុងស្ថានភាពបច្ចុប្បន្ននៃការអប់រំ យើងខ្ញុំបានសង្កេតឃើញឧបសគ្គរាំងជំនើរឈានឡើងទៅរកការអភិវឌ្ឍន៍ពេញបរិបូរណ៍នៃការបណ្តុះបណ្តាលធនធានមនុស្ស ។ ភាពក្រីក្រទុគតិ ភាពអនាធិបតេយ្យ និងភាពស្រុតចុះនៃសីលធម៌សង្គម និងសីលធម៌បុគ្គល ធ្វើអោយសង្គមកម្ពុជាក្លាយបន្តិចម្តងៗ ជាសង្គមខ្វះសេចក្តីថ្លៃថ្នូរ ។ អំពើហឹង្សាឃោរឃៅ អំពើលួចប្លន់ កាប់សំលាប់ និង អំពើអនាចារគ្រប់រូបភាព យើងបានឃើញលើគ្រប់ទំព័រកាសែតរាល់ថ្ងៃ ។ តំលៃមនុស្ស តំលៃជាតិ ត្រូវបានស្រុតចុះ និងប្រែប្រួលជាខ្លាំង ។ គេធ្លាប់តែសរសើរខ្មែរពីការរស់នៅត្រឹមត្រូវតាមសីលធម៌ ។ តែឥឡូវនេះ ត្រូវគេថ្កោលទោសទៅវិញ ។ តំលៃមនុស្សកើតមក រឺ បានមកជាបឋមពីការចេះ និងការដឹង គឺដឹងល្អ ដឹងអាក្រក់ ដឹងគុណ ដឹងទោស ។ល ។

ការអប់រំជាផ្នែកមួយអោយធនធានមនុស្សមានចំនេះដឹង មានសមត្ថភាពក្នុងការងារ មានចរិយាធម៌ត្រឹមត្រូវ ។ ជារួម អោយមនុស្ស និងសង្គមមានតំលៃ ( valeur de l'homme et de la societé ) ។ ដូចនេះ ថ្វីត្បិតតែការអប់រំជាបញ្ហាស្មុគស្មាញ ពិបាកដោះស្រាយយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលត្រូវតែគិត ត្រូវតែពុះពារបំផុសអោយប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ យល់បានជ្រួតជ្រាបពីតំលៃនៃវិជ្ជា ។ ការទុកបណ្តោយអោយតំលៃជាតិស្រុតចុះទៅៗ នោះ យើងមិនងាយនឹងស្តារឡើងវិញបានឡើយ ។ ការអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សទាមទារការងារអំណត់អត់ធន់ និងសន្សឹមៗ តែងំជានិច្ចក្នុងរយៈពេលដ៏យូរ ។ ម្យ៉ាងទៀត ការអប់រំអោយបានទាំងអស់គ្នា ជាបឋម ត្រូវប្រមូល និងប្រើប្រាស់ធនធានក្នុងប្រទេសអោយអស់លទ្ធភាពដែលយើងធ្លាប់ហៅថាកំលាំងសរុប ។ អង្គការអន្តរជាតិ ទទួលបន្ទុកអប់រំមនុស្សលើភពផែនដីនឹងជួយយើង កាលណាគេឃើញយើងមានឆន្ទៈ និងការខំប្រឹងដ៏មុតមាំជាមុនសិន ។ ឆន្ទៈដ៏មោះមុត និងការខំប្រឹងជាប្រចាំក្នុងការអនុវត្តយុទ្ធវិធីអប់រំ កើតពីការព្រមព្រៀងគ្នាជាឯកច្ឆន្ទ ( Consensus national ) និងការប្តេជ្ញាចិត្តនៃប្រជាពលរដ្ឋទូទាំងប្រទេស ( Engagement de tous ) ។ ចលករទាំងពីរនេះ រួមផ្សំនឹងការកំនត់ពេលវែង ( long terme ) ជាល័ក្ខខ័ណ្ឌនៃជ័យជំនះ ។

ជារួម ការអភិវឌ្ឍន៍សង្គម - សេដ្ឋកិច្ចនៃប្រទេសនីមួយៗ នឹងរីកចំរើនទៅបាន លុះត្រាតែវប្បធម៌ជាតិត្រូវបានអភិវឌ្ឍទៅទន្ទឹមគ្នា ។

ដោយ **យ៉ង់ ធី**



# សកម្មភាពបំផុសចលនាសាលារៀន - សហគមន៍
# ឆ្នាំសិក្សា ១៩៩៦ - ៩៧



ផ្តើមចេញពីទិសដៅជាយុទ្ធសាស្ត្រ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានដាក់ចេញថា : « ការអប់រំ គឺជាភារកិច្ចរបស់យើងទាំងអស់គ្នា » ឆ្នាំសិក្សា 1996 - 97 ក៏ដូចជាឆ្នាំសិក្សាកន្លងទៅ គណៈកម្មការបំផុស បានចាត់ចែង អោយមានការប្រកួតខាងកីឡា - សិល្បៈសិស្សបឋមសិក្សា និងការប្រលងប្រណាំងសាលារៀនលើប្រធានបទ « សាលារៀន យើងមានការប្រែប្រួល » ។

នៅទូទាំងប្រទេសយើងមានសាលារៀនបឋមសិក្សាចំនួន 4652 សាលា ក្នុងនោះសាលារៀនប្រមាណជា3400 សាលាបានចូលរួមក្នុងការប្រកួតខាងកីឡា សាលារៀនចំនួន 1 100 បានចូលរៀនប្រកួតខាងសិល្បៈ និងមានសហគមន៍ចំនួន 4 100 បានចូលរួមក្នុងការប្រលងប្រណាំងសាលារៀន ។ ការប្រកួតខាងកីឡា និងសិល្បៈនៅថ្នាក់ស្រុក ខ័ណ្ឌ បានប្រព្រឹត្តទៅពីថ្ងៃ 24 - 28 ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និងនៅថ្នាក់ខេត្ត - ក្រុង ចាប់ពីថ្ងៃទី 27 - 30 ខែ មីនា ឆ្នាំ 1997 ។ ដោយឡែកការប្រលងប្រណាំងសាលារៀន ថ្នាក់ស្រុក - ខ័ណ្ឌបានប្រព្រឹត្តទៅពីថ្ងៃទី 7 ដល់ 10 ខែ មេសា ឆ្នាំ 1997 និងបានជ្រើសរើសបញ្ចប់នៅថ្នាក់ខេត្ត - ក្រុងកាលពីចុងខែ មេសា ឆ្នាំ 1997 ហើយគណៈកម្មការបានធ្វើការជ្រើសរើសសំរាំងនូវសាលារៀនចំនួន **101** សាលា ដែលសាលារៀននីមួយៗ នឹងត្រូវបានទទួលរង្វាន់ចំនួន **200** ដុល្លា ជាទុនសំរាប់យកទៅប្រើប្រាស់ដើម្បីជាគុណប្រយោជន៍រួមរបស់សាលានីមួយៗ ។ ការប្រកួតថ្នាក់ជាតិផ្នែកីឡា - សិល្បៈ បានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញពីថ្ងៃទី 29 - 31 ខែ ឧសភា ឆ្នាំ 1997 ដែលរួមមានក្រុមកីឡា និងសិល្បៈសិស្សសាលារៀនបឋមសិក្សាដែលជាប់បំនាច់ថ្នាក់លេខ **1** តាមខេត្ត - ក្រុងទាំង **22**មកចូលរួម សរុបចំនួនចូលរួមទាំងអស់មានចំនួន **800** នាក់ ។

## លទ្ធផលថ្នាក់ផ្តាច់ព្រ័តថ្នាក់ជាតិខាងកីឡា

**លេខ ១** សាលារៀន ពោធិលង្កា ស្រុកសៀមរាប ខេត្តសៀមរាប

**លេខ ២** សាលារៀន ពាមឆ្កោក ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង

**លេខ ៣** សាលារៀន ជ្រោយបន្ទាយ ស្រុកព្រែកប្រសប់ ខេត្តក្រចេះ

## លទ្ធផលថ្នាក់ផ្តាច់ព្រ័តថ្នាក់ជាតិខាងសិល្បៈ

**លេខ ១** សាលារៀន ទីរួមខេត្ត ស្រុកស្មាច់មានជ័យ ខេត្តកោះកុង

**លេខ ២** សាលារៀន គំរូក្រុង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
**លេខ ៣** សាលារៀន គោកសណ្តែក ស្រុកបាភ្នំ ខេត្តព្រៃវែង



**រង្វាន់សំរាប់ជ័យលាភី ផ្នែកកីឡា - សិល្បៈ**

**១. ផ្នែកកីឡា :**

- **រង្វាន់លេខ ១** ទឹកប្រាក់ចំនួន **4 500 ដុល្លារសហរដ្ឋអាមេរិក** ក្នុងនោះ
  - **500** ដុល្លា ជាព្រះប្រទានរបស់ព្រះមហាក្សត្រ និងព្រះរាជអគ្គមហេសី
  - **4 000** ដុល្លា ជាអំណោយរបស់ធនាគារឥណ្ឌូស៊ុយអេស៍
- **រង្វាន់លេខ ២** ទទួលបានប្រាក់ចំនួន **3000 ដុល្លារសហរដ្ឋអាមេរិក**
- **រង្វាន់លេខ ៣** ទទួលបានប្រាក់ចំនួន **2 500 ដុល្លារសហរដ្ឋអាមេរិក**

**២. ផ្នែកសិល្បៈ :**

- **រង្វាន់លេខ ១** ទទួលបានប្រាក់ចំនួន **4 500 ដុល្លារសហរដ្ឋអាមេរិក**
- **រង្វាន់លេខ ២** ទទួលបានប្រាក់ចំនួន **3000 ដុល្លារសហរដ្ឋអាមេរិក**
- **រង្វាន់លេខ ៣** ទទួលបានប្រាក់ចំនួន **2 500 ដុល្លារសហរដ្ឋអាមេរិក**

ក្នុងពិធីចែករង្វាន់ដល់ជ័យលាភីនៅសាលសន្និសីទចតុមុខ គណៈកម្មការរៀបចំការប្រកួត បានទទួលនូវមហាកិត្តិយសដ៏ឧត្តុង្គឧត្តមបំផុត ដោយបានការអញ្ជើញចូលរួមរបស់សម្តេច **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ **ព្រះមហាក្សត្រ** និង **ព្រះរាជអគ្គមហេសី** និងសម្តេច **ហេង សំរិន** សមាជិកឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់ព្រះរាជបល្ល័ង្ក ។



# សកម្មភាពគណៈកម្មការនារី ក្រសួងអប់រំ យុវជន និង កីឡា



គណៈកម្មការនារីក្រសួងអប់រំ យុវជន និង កីឡា បានប្រសូតិឡើងក្នុងឆ្នាំ ១៩៨០ ជាបណ្ដាញសាខារបស់សមាគមនារីកម្ពុជារហូតដល់ឆ្នាំ ១៩៩៣ ។

ក្រោយការបោះឆ្នោតជាសាកលក្នុងឆ្នាំ ១៩៩៣ រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ដែលបច្ចុប្បន្ន ជាក្រសួងកិច្ចការនារីបានផ្ញើជូនដល់គ្រប់ក្រសួងមន្ទីរទាំងអស់ អោយជ្រើសរើសតំណាងនារីសំរាប់ការពារផលប្រយោជន៍ស្ត្រី តាមស្ថាប័នរៀងៗខ្លួន ។

លោកស្រី **ហួរ ស៊ី** ប្រធានស្ដីទី នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ ត្រូវបានចាត់តាំងជាប្រធានគណៈកម្មការនារីក្រសួងអប់រំ យុវជន និងកីឡា ដែលមានលោកស្រី **គាន នារី** ប្រធានការិយាល័យនាយកដ្ឋានឧត្តមសិក្សា និងលោកស្រី **ច្រាក់ សុលីដា** នាយិកា សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ជាអនុប្រធាន និងសមាជិក ៦រូបទៀត គឺលោកស្រី **ហង់ តារី** លោកស្រី **គៀង សកុណា** កញ្ញា **ជិន ណាប៊ូ** លោកស្រី **គីម មូលីដា** លោកស្រី **កុយ ចណ្ណារី** និងលោកស្រី **សំ យិន** ។

## ១. គោលបំនង

គោលបំនង និងសំនូមពររបស់គណៈកម្មការនារីក្រសួងអប់រំ យុវជន និងកីឡាគឺ :

* ចង់អោយនារីក្រសួងអប់រំ យុវជន និងកីឡា យល់ដឹងច្បាស់លាស់ពីសិទ្ធិ និងតួនាទីរបស់ខ្លួនតាមភារកិច្ចដែលក្រសួងបានចាត់តាំង ។

* ជំរុញនារីក្នុងវិស័យអប់រំអោយម្ចាស់ការធ្វើការអភិវឌ្ឍន៍ បង្កើនស្មារតីទទួលខុសត្រូវ និងចូលរួមធ្វើសេចក្ដីសំរេចនានាដោយអង់អាចក្លាហាន ។

* មានសាមគ្គីភាពផ្ទៃក្នុងក្រសួងល្អ ចេះទំនាក់ទំនង និងសាមគ្គីទូលំទូលាយជាមួយនារីអន្តរក្រសួង នារីអន្តរជាតិ ជាពិសេសត្រូវគិតគូរជានិច្ចថា ខ្លួនជាដៃគូយ៉ាងមានប្រសិទ្ធភាពបំផុតជាមួយបងប្អូនបុរសក្នុងការអភិវឌ្ឍន៍ការងារក្នុងគ្រួសារ សង្គម និងប្រទេសជាតិ ។

## ២. ភារៈកិច្ចរបស់គណៈកម្មការនារី

ផ្អែកលើគោលបំនង និងសំនូមពរខាងលើ គណៈកម្មការនេះមានភារកិច្ចបំរើ និងដោះស្រាយបញ្ហានារីនៅតាមអង្គភាពក្រោមឱវាទទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចំនួន ២៧ ដែលមានសមាជិកនារីទាំងអស់ចំនួន ៩៦៨ នាក់ដូចខាងក្រោម :

១. រៀបចំផែនការ និងសកម្មភាពការងារនារីក្នុងក្រសួងអប់រំ យុវជន និងកីឡា

២. បំផុសស្មារតីនារីចូលរួមគ្រប់សកម្មភាពជំនាញតាមអង្គភាពនីមួយៗ

៣. សហការជាមួយក្រសួងកិច្ចការនារី និងអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានាលើគ្រប់សកម្មភាពនារីពាក់ព័ន្ធលើវិស័យអប់រំ

៤. លើកសំនើ និងផ្តល់យោបល់ដល់ថ្នាក់ដឹកនាំក្រសួងក្នុងការចាត់តាំងនារីចូលរួមប្រជុំ សិក្ខាសាលាជាតិ អន្តរជាតិក្នុង និងក្រៅប្រទេស និងរៀបចំពិធីបុណ្យផ្សេងៗ មានជាអាទិ៍បុណ្យទិវានារីអន្តរជាតិ ៨មីនា ជារៀងរាល់ឆ្នាំ

៥. ចុះសួរសុខទុក្ខបងប្អូននារី

## ៣. ផែនការសកម្មភាពការងាររបស់គណៈកម្មការនារីឆ្នាំ ១៩៩៧ - ១៩៩៩

អនុវត្តតាមខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្នុងជំពូក ៦មាត្រា ៦៥ ៦៦ ៦៧ និង៦៨ ស្តីពីការងារអប់រំ គណៈកម្មការនារី បានដាក់ចេញគោលនយោបាយដែលមានចរិតជាក់ស្តែងឆ្លើយតបសំនូមពរនៃតថភាពអប់រំរបស់ប្រទេសជាតិសមស្របនឹងទស្សនៈ « **ការអប់រំសំរាប់ទាំងអស់គ្នា** » របស់ចរន្តអប់រំសកលលោក ។ ក្នុងន័យនេះ យុទ្ធវិធីរួម និងដោយឡែកគិតគូរដល់នារីភេទ ឆ្នាំ ១៩៩៧ - ៩៩មាន :

១. ខិតខំធ្វើស្ថិតិជំរឿនកុមារ ចលនាកុមារក្នុងវ័យសិក្សា និងដល់វ័យសិក្សាអោយចូលរៀនបានគ្រប់ៗ គ្នា ។ ទន្ទឹមនោះយកចិត្តទុកដាក់ចំពោះកុមារីនៅតំបន់ដាច់ស្រយាល ជនជាតិភាគតិច និងតំបន់ព្រៃភ្នំ

២. រៀបចំគោលនយោបាយ កសាងអន្តេវាសិកដ្ឋាន ផ្តល់អាហារូបត្ថម្ភដល់សិស្សជួបការលំបាក ពិសេសជួបការលំបាកជានារីភេទនៅតំបន់ព្រៃភ្នំ និងតំបន់ដាច់ស្រយាល

៣. បង្កលក្ខណៈ និងជំរុញសិស្សនារីអោយបានច្រើនរៀនដល់ឧត្តមសិក្សា ដោយផ្តល់អាទិភាពក្នុងការប្រឡងចូល និងទីកន្លែងស្នាក់នៅ

៤. បញ្ចូលតាមរយៈកម្មវិធី និងសៀវភៅសិក្សាថ្មីលើគ្រប់មុខវិជ្ជា នូវខ្លឹមសារគំលាតភេទ « gender gap » រវាងសិស្សប្រុស និងសិស្សស្រី

៥. លើកកំពស់ការងារអប់រំ យុវជន យុវតី និងការហ្វឹកហ្វឺនអប់រំកាយ និងកីឡា

៦. លើកដំកើងការអភិវឌ្ឍន៍ស្ត្រី តាមរយៈការលើកកំពស់កំរិតវប្បធម៌ទូទៅ និងចំនេះដឹងខាងមុខរបរ

# ទស្សនៈខ្លះៗ ក្នុងការអប់រំនារី ដែលគួរពិចារណា

ខ្ញុំ **ម្ហូរ ស៊ី** ប្រធានស្ដីទីនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ បានទៅធ្វើទស្សនកិច្ចសិក្សាដកពិសោធន៍ការងារអប់រំនៅប្រទេស សេរីលង្កា នៅឆ្នាំ ១៩៩៥ ។ ខ្ញុំបានជួប សំណេះសំណាលជាមួយគ្រួសារក្រីក្រមួយ មានកូន ២នាក់ក្នុងបន្ទុក គឺប្រុសមួយ ស្រីមួយ ។ **ខ្ញុំសែនឆ្ងល់ ដោយគ្រួសារនេះបញ្ជូនកូនស្រីអោយទៅរៀន** រីឯកូនប្រុសគាត់ទុកនៅផ្ទះដោយជីវភាពរស់នៅក្រលំបាកពេក ។ ពេលខ្ញុំសួរគាត់ គាត់ឆ្លើយថា : « កូនប្រុសមានកំលាំង អាចធ្វើការងារអ្វីបានគ្រប់យ៉ាងដើម្បីចិញ្ចឹមជីវិតទៅអនាគត បើកូនប្រុសនោះមិនចេះអក្សរ ក៏មិនប៉ះពាល់ដល់សង្គមខ្លាំងក្លាដែរ ។ **រីឯកូនស្រី គឺជាការពិបាក ព្រោះកំលាំងទន់ខ្សោយ ហើយនាអនាគតក្លាយទៅជាមេផ្ទះអប់រំកូនក្នុងគ្រួសារដែលជាកោសិការបស់សង្គម និងប្រទេសជាតិ** បើស្ត្រីចេះអក្សរ វាជាកត្តាមួយសំខាន់បំផុតនៅក្នុងការធ្វើអោយបានជោគជ័យនូវផែនការពន្យាកំនើត និងការរក្សាសុខភាពជាមូលដ្ឋានក្នុងគ្រួសារក៏ដូចជាក្នុងសង្គមជាតិទាំងមូល ជាពិសេសក្នុងការចូលរួមអប់រំកូនប្រុស និងកូនស្រីអោយមានចំនេះដឹងស្មើគ្នាចេះបែងចែកការងាររវាងសមាជិកគ្រួសារទាំងប្រុស ទាំងស្រីអោយស្គាល់តួនាទី និងសិទ្ធិរៀងខ្លួនៗ ដោយមិនប្រកាន់ភេទ ។

ខ្ញុំ **តឿន សកុណា** ប្រធានមហាវិទ្យាល័យគីមី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សូមនាំនារីយើងក្រឡេកមើលសេចក្ដីក្លាហានក្នុងការដឹកនាំ ព្រមទាំងតួនាទីរបស់ស្ត្រីខ្មែរនាបុរាណសម័យ ។ ព្រះនាងសោមា រឺព្រះនាង លិវយី ជាស្ត្រីខ្មែរទីមួយ ដែលដឹកនាំទឹកដីគោកធ្លក អោយមានរូបរាងជានគរនិតិរដ្ឋ មានច្បាប់ទំលាប់ និងអារ្យធម៌ពិសេសរបស់ខ្លួន ។

ព្រះនាងឥន្ទ្រទេវី ជាអគ្គមហេសីនៃព្រះបាទជ័យវរ្ម័នទី ៧ មានតួនាទី ជាសកលវិទ្យាធិការនៃមហាវិទ្យាល័យពហុបច្ចេកវិទ្យា វិបស្សនាក្នុងប្រាសាទព្រះខ័ន និងមហាវិទ្យាល័យវេជ្ជសាស្ត្រវិបស្សនាក្នុងប្រាសាទតាព្រហ្ម ។ មន្ត្រីៗ ដែលជាអ្នកកាន់កាប់វាសនាប្រទេសជាតិ និងមេទ័ពទាំងអស់ សុទ្ធតែត្រូវបានឆ្លងកាត់មហាវិទ្យាល័យមួយ ក្នុងចំនោមមហាវិទ្យាល័យទាំងពីរមុននឹងចូលទទួលខុសត្រូវក្នុងមុខតំណែងរបស់ខ្លួន ។ ការតែងតាំងស្ត្រីជាធំ ទទួលបន្ទុកអប់រំអនាគតអ្នកដឹកនាំប្រទេស រឹតតែធ្វើអោយឃើញច្បាស់នូវចិត្តគំនិតរបស់ខ្មែរដើមចំពោះតំលៃនារី ។

សង្គ្រាមដែលកើតមានជាបន្តបន្ទាប់ ការចាកចោលទីក្រុងអង្គរ ការបែកបាក់បន្ទាយលង្វែក និងការរឹករដែលមានជាហូរហែបានធ្វើអោយមានការផ្លាស់ប្ដូរយ៉ាងធំក្នុងផ្នត់គំនិតសង្គមខ្មែរ ។ បន្តិចម្ដងៗ ការនិយមភាពទន់ភ្លន់ហ្មត់ចត់ និងឈ្លាសវៃត្រូវបានជំនួសដោយការនិយមកំលាំងបាយរបស់បុរស ហើយប្រពៃណីតឹងរឹងមួយចំនួនក៏បានត្រូវបង្កើតឡើងដើម្បីកំនត់ព្រំដែនរបស់នារី ដែលមានសល់ជាបន្តរហូតមកដល់សម័យបច្ចុប្បននេះ ។

បើយើងក្រលេកមើលសេចក្ដីក្លាហានក្នុងការដឹកនាំព្រមទាំងតួនាទីរបស់ស្ត្រីខ្មែរនាបុរាណកាល និងភាពទន់ខ្សោយភ្លើតភ្លើនអវិជ្ជារបស់ស្ត្រីខ្មែរភាគច្រើននាពេលបច្ចុប្បន្ន យើងទាំងអស់គ្នានឹងយល់ភ្លាមថា តើគេត្រូវផ្ដោតការយកចិត្តទុកដាក់ខ្លាំងក្លាដល់កំរិតណាលើស្ត្រីខ្មែរ បើចង់អោយសង្គមខ្មែរលូតលាស់រីកចំរើនដូចអរិយប្រទេសនានាក្នុងសភាពជាក់ស្ដែង ដែលកំលាំងពលកម្មជាភេទនារី មានភាគរយច្រើនជាបុរស !

ខ្ញុំ **ប្រាក់ សុលីដា** នាយិកាសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ខ្ញុំសូមសួរថា តើនារីយើងពិតជាមានលទ្ធភាពធ្វើសេចក្តីសំរេចដោយខ្លួនឯងបានដែររឺទេ ? ហើយខ្ញុំក៏សូមជូនចំលើយតាមគំនិតផ្ទាល់ដើម្បីពិចារណាដូចតទៅ :

ទស្សនៈក្នុងសង្គមតែងតែចាត់ទុកថា នារីពុំអាចធ្វើអ្វីបានគ្រប់យ៉ាងដូចបុរស តែទស្សនៈបែបនេះពិតជាពុំត្រឹមត្រូវឡើយ តាមពិតនារីគ្រប់រូបមានលទ្ធភាពធ្វើសេចក្តីសំរេចបានដូចបុរសដែរ ។ បើក្រលេកមើលទៅលើពិភពលោក យើងនេះមានស្ត្រីបានទទួលតួនាទីសំខាន់ៗ ដូចជា នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ឯកអគ្គរដ្ឋទូត លេខាធិការ អនុលេខាធិការ ប្រធានមន្ទីរ អនុប្រធានមន្ទីរ ប្រធាន អនុប្រធាននាយកដ្ឋាន អភិបាលស្រុក វេជ្ជបណ្ឌិត សាស្ត្រាចារ្យ នាយិកាសាលា វិស្វករ ស្ថាបត្យករ សិល្បករ ប្រធានក្រុមហ៊ុន អ្នកយកពត៌មាន . . . ។ល ។ តួនាទីទាំងអស់នេះ ពិតជាបានមកពីការខិតខំរបស់ស្ត្រីក្នុងការពង្រីកចំនេះដឹង មានការតស៊ូ អំណត់ព្យាយាម សេចក្តីក្លាហាន មានជំនឿជាក់លើខ្លួនឯង មានទំនាក់ទំនងល្អជាមួយបុរស និងមនុស្សទូទៅ ។ ឧទាហរណ៍ជាក់ស្តែង នៅពេលដែលខ្ញុំបានទៅធ្វើទស្សនកិច្ចនៅប្រទេស ហ្វីលីពីន ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៩៧ថ្មីៗ នេះ ខ្ញុំមានការភ្ញាក់ផ្អើល និងកោតសរសើរយ៉ាងខ្លាំងដោយឃើញប្រទេសនេះមាននារីជាច្រើន មានតួនាទីសំខាន់ៗ ក្នុងរដ្ឋាភិបាល ក្នុងមន្ទីរក្រសួងក៏ដូចជាក្នុងសហគមន៍ ។

ដូចនេះ តើសង្គមខ្មែរគួរផ្តល់លទ្ធភាព និងយកចិត្តទុកដាក់ដល់នារីដោយវិធីណា ដើម្បីជំរុញបានច្រើនចូលរួមធ្វើសេចក្តីសំរេចដោយខ្លួនឯង ?

ដោយលោកស្រី **ហួរ ស៊ីរី**

- **តៀង សកុណា**
- **ប្រាក់ សុលីដា**

**អប់រំនារីមួយនាក់ គឺអប់រំប្រជាជាតិទាំងមូល**




**ពិធីជូនពរសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីសកល ឆ្នាំ1997**

# ការបណ្តុះបណ្តាលគ្រូបង្រៀនភាសាបារាំង ក្នុងក្របខ័ណ្ឌហ្វ្រង់កូហ្វូនី

## Formation des enseignants de français dans le cadre de la francophonie

ហ្វ្រង់កូហ្វូនីគឺសំដៅលើប្រទេសចំនួន ៤៩ លើសកលលោក ដែលនិយាយភាសាបារាំង ។ ប្រទេសកម្ពុជាយើងក៏ជាសមាជិកមួយនៃហ្វ្រង់កូហ្វូនីដែរ ។ ប៉ុន្តែ ដោយសារសង្គ្រាមជាងពីរទសវត្សចុងក្រោយនេះ សកម្មភាពនៃហ្វ្រង់កូហ្វូនីពោលគឺការនិយាយភាសាបារាំង និងការប្រើប្រាស់ភាសាបារាំងនៅកម្ពុជាយើង ត្រូវអសកម្ម និងរាំងស្ទះស្ទើរតែរលាយសាបសូន្យ ។

ឆ្នាំ ១៩៩៣ ស្របទៅតាមសំនូមពរអភិវឌ្ឍន៍នៃសង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំនត់ច្បាស់ពីនយោបាយអប់រំ ដែលបច្ចុប្បន្ននេះទាមទារអោយត្រូវលើកកំពស់គុណភាព ក្នុងនោះយកចិត្តទុកដាក់ដល់ការពង្រឹងវិទ្យាសាស្ត្របច្ចេកវិទ្យា និងភាសាបរទេស ។

ផ្តើមចេញពីនេះ ការបង្រៀនភាសាបារាំងក៏ដូចជាភាសាអង់គ្លេស ត្រូវបានកែលំអ និង ជំរុញថែមទៀតនៅតាមសាលារៀន និងគ្រឹះស្ថានសិក្សានានាក្នុងទូទាំងប្រទេស ។




ក្នុងគោលដៅជំរុញលើកទឹកចិត្ត និងបង្កលក្ខណៈដល់ការបង្រៀន និងការរៀនភាសាបារាំងនៅក្នុងប្រទេសនានាជាសមាជិកហ្វ្រង់កូហ្វូនីនោះ មជ្ឈមណ្ឌលហ្វ្រង់កូហ្វូនី អាស៊ីប៉ាស៊ីហ្វិច (CREFAP) ត្រូវបានបង្កើតឡើងនៅទីក្រុងហូជីមិញ ប្រទេសវៀតណាមក្នុងឆ្នាំ ១៩៩៣ ក្រោមការទទួលខុសត្រូវរបស់សាលាអន្តរជាតិ ហ្វ្រង់កូហ្វូនី ដែលមានទីតាំងនៅទីក្រុងប៊ីរដូប្រទេសបារាំង ។ បន្ទាប់មកនៅឆ្នាំ ១៩៩៥ ការិយាល័យតំបន់អាស៊ីប៉ាស៊ីហ្វិច (BRAP) ក៏ត្រូវបានបង្កើតឡើងទៀត នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

ចាប់តាំងពីឆ្នាំ ១៩៩៣ ក្រោមការឧបត្ថម្ភរបស់ទីភ្នាក់ងារសហប្រតិបត្តិការវប្បធម៌បច្ចេកទេសហ្វ្រង់កូហ្វូនី (ACCT) និងសាលាអន្តរជាតិប៊ីរដូ (EIB) ប្រទេសទាំងបួននៅតំបន់អាស៊ីប៉ាស៊ីហ្វិច កម្ពុជា ឡាវ វៀតណាម និងវ៉ានូយអាទូ បានបញ្ជូនគ្រូភាសាបារាំងអោយទៅបំពេញកម្មសិក្សា និងសិក្ខាសាលា ដើម្បីបង្កើនសមត្ថភាពបង្រៀនភាសាបារាំងសំរាប់កម្មវិធីបឋមសិក្សា និងមធ្យមសិក្សាចំនួនពី ៥ ទៅ ៦លើក ក្នុងមួយឆ្នាំៗ នៅ CREFAP នាទីក្រុងហូជីមិញ ក្នុងនោះមានសិក្ខាកាមកម្ពុជាប្រមាណជាង ២០នាក់ ។

បន្ទាប់មក ដោយផ្អែកទៅលើគោលគំនិតសំខាន់នៃសហប្រតិបត្តិការពហុភាគីដែលថា ការបណ្តុះបណ្តាលទាំងឡាយអាចធ្វើឡើងជាដៃគូស្នេហភាពជាមួយគ្រឹះស្ថាននានា ដែលស្ថិតនៅក្នុងប្រទេសជាសមាជិកនោះ ទើបនៅឆ្នាំ ១៩៩៧

នេះ វគ្គបណ្ដុះបណ្ដាលមួយឈ្មោះថា « កម្មសិក្សាគរុកោសល្យសំរាប់សាស្ត្រាចារ្យឧទ្ទេសភាសាបារាំង » ត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ នៅមហាវិទ្យាល័យគរុកោសល្យរយៈពេល ៤ សប្ដាហ៍ គឺពីថ្ងៃទី ៣១ មីនា ដល់ថ្ងៃ ២៥ មេសា ១៩៩៧ ដោយមានកម្មសិក្សាការីមកពីប្រទេសឡាវ ៤នាក់ វៀតណាម ៥នាក់ វ៉ានុយអាទូ ១នាក់ និងកម្ពុជា ១៩នាក់ ។



ខ្លឹមសារនៃកម្មវិធីសិក្សានេះ ត្រូវបានរៀបចំឡើងដោយប្រមូលផ្ដុំទៅលើវិធីសាស្ត្របង្រៀន និងរៀនភាសាបារាំងនៅមធ្យមសិក្សា ក្នុងនោះយកចិត្តទុកដាក់ ជាពិសេស លើការលើកកំពស់សមត្ថភាពទាំង ៤ នៃភាសា គឺយល់ពីការនិយាយ យល់ពីការសរសេរ ចេះនិយាយ និងចេះសរសេរ ។

គោលដៅនៃកម្មសិក្សានេះ គឺផ្ដល់នូវសមត្ថភាពគរុកោសល្យពេញលេញ ប៉ិនប្រសប់ និងម្ចាស់ការអោយដល់សិក្ខាកាមទាំងអស់ ដើម្បីវិលត្រលប់ទៅវិញរៀបចំបំប៉នបន្តជូនដល់គ្រូបង្រៀន ដែលកំពុងបង្រៀនភាសាបារាំងនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនានាអោយបានកាន់តែល្អប្រសើរ ញ៉ាំងអោយសកម្មភាពហ្វ្រង់កូហ្វូនីនៅតំបន់អាស៊ីប៉ាស៊ីហ្វិច កាន់តែត្រូវបានពង្រឹង និងពង្រីកថែមទៀត ។

ក្រៅពីការបំប៉នគ្រូបង្រៀនភាសាបារាំងតាមរយៈផែនការហ្វ្រង់កូហ្វូនីនេះ យើងបានបណ្ដុះបណ្ដាល និងបំប៉នគ្រូបង្រៀនភាសាបារាំងជាច្រើនទៀតប្រមាណ ១៨០០នាក់ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលវប្បធម៌បារាំង « C.C.C.L » និងជាមួយ AUPELF - UREF ។

ដោយលោក **អ៊ុំ សយ**

និងកែសំរួលដោយលោក **ឆាន មុត**






# ស្នេហាមាតុភូមិ

**( Patriotisme )**

ការបណ្ដុះមនុស្សអោយមានទឹកចិត្តស្នេហាមាតុភូមិ គឺជាការចាំបាច់ ។ សេចក្ដីស្នេហាមាតុភូមិមានសារប្រយោជន៍សំរាប់ការពារ និងកសាងប្រទេសនីមួយៗ ឈានទៅរកវឌ្ឍនភាពពិតប្រាកដ ។

## ១. ស្នេហាមាតុភូមិជាអ្វី ?

ស្នេហាមាតុភូមិជាសញ្ចេតនាដ៏ជ្រាលជ្រៅ ប្រកបដោយភក្ដីភាពហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីការពារមាតុភូមិ ជាពិសេសហ៊ានធ្វើពលិកម្មដើម្បីប្រឆាំងចំពោះការឈ្លានពានដោយកំលាំងអាវុធរបស់សត្រូវ ។

ស្នេហាមាតុភូមិធ្វើអោយពលរដ្ឋម្នាក់ៗ យល់ច្បាស់ ៖

- **អំពីសេចក្ដីស្មោះត្រង់របស់ខ្លួនចំពោះមាតុភូមិ ។**
- **អំពីករណីយកិច្ចរបស់ខ្លួនចំពោះអរិយធម៌ជាតិ ។**
- **អំពីស្មារតីលះបង់ខ្ពស់របស់ខ្លួន ដោយហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីផលប្រយោជន៍មាតុភូមិ ។**

ហេតុនេះ ស្នេហាមាតុភូមិជាកំលាំងដ៏ធំមួយសំរាប់ជំរុញអោយសង្គមឈានទៅរកវឌ្ឍនភាព ។ អ្នកដឹកនាំបញ្ញវន្ត និស្សិត យុទ្ធជន កម្មករ និងកសិករ ដែលមានគំនិតស្នេហាមាតុភូមិ តែងបំពេញកាតព្វកិច្ចប្រកបដោយអារម្មណ៍មួយថា : « អ្វីៗ ទាំងអស់ គឺដើម្បីមាតុភូមិជាទីស្នេហារបស់យើង » ។

## ២. តើស្នេហាមាតុភូមិស្ដែងឡើងយ៉ាងដូចម្ដេច ?

ស្នេហាមាតុភូមិមិនស្ថិតនៅក្នុងភាពអាថិកំបាំងទេ តែវាស្ដែងឡើងអោយឃើញជាក់ច្បាស់បំផុត ។ នៅសម័យសន្តិភាព អ្នកស្នេហាមាតុភូមិតែងខិតខំរួមចំណែកលើកកំពស់ជីវភាពសំភារៈ និងស្មារតីរបស់ប្រជាជន ។ នៅសម័យសង្គ្រាមឈ្លានពាន គេហ៊ានធ្វើពលិកម្មរហូតដល់ដំណក់ឈាមចុងក្រោយ ។ គេអាចសំរេចកិច្ចការនេះបាន លុះត្រាតែគេមានសេចក្ដីឈ្លាសវៃ មានគំនិតភ្លឺថ្លា និងមានសេចក្ដីព្យាយាមចំពោះការងារ ។

ដើម្បីស្ដែងអោយឃើញពីស្នេហាមាតុភូមិបរិសុទ្ធ ពលរដ្ឋគ្រប់រូបត្រូវប្រឆាំងចំពោះទស្សនៈពីរបែបគឺ :

. ទស្សនៈសាកលនិយម ( Universalisme ) : ទស្សនៈសាកលនិយមតែងបដិសេធវប្បធម៌ជាតិ និងប្រពៃណីជាតិ ។ ជនណាមានទស្សនៈសាកលនិយម ជននោះបាត់បង់អស់ទស្សនៈមោទនភាពជាតិ រហូតដល់ហ៊ានលក់ដូរផលប្រយោជន៍មាតុភូមិទៀតផង ។

. ទស្សនៈជាតិនិយមហួសហេតុ ( Nationalisme extrémiste ) : ទស្សនៈជាតិនិយមហួសហេតុតែងគិតតែពីផលប្រយោជន៍របស់ជាតិខ្លួន និងផលប្រយោជន៍ផ្ទាល់ខ្លួន ហើយមានបំណងបំផ្លិចបំផ្លាញផលប្រយោជន៍នៃប្រទេសដទៃ ។ ទស្សនៈនេះបំផ្លិចបំផ្លាញស្មារតីសាមគ្គីអន្តរជាតិ ដោយធ្វើអោយមនុស្សមានអាកប្បកិរិយាឆ្មើងឆ្មៃ កន្ទ្រើងយល់ថា មានតែជាតិខ្លួនទេដែលសាមគ្គីខ្ពស់ជាងជាតិដទៃទៀត ។

## ៣. តើគួរអប់រំបែបណា ដើម្បីអោយពលរដ្ឋគ្រប់រូបមានទស្សនៈស្នេហាមាតុភូមិ ?

គ្រួសារ សាលារៀន និងសង្គមមានទាទីអប់រំអោយកុមារ យុវជន និងមនុស្សពេញវ័យស្រលាញ់ភាសា អរិយធម៌ វប្បធម៌ ប្រពៃណី ប្រវត្តិសាស្ត្រ និងមានមោទនភាពជាតិ ដោយលះបង់ចោលគំនិតពីរបែបគឺ ហីនមានៈ ( Complexe d'infériorité ) ដែលយល់ថាខ្លួនតូចទាបជាងគេពេក និងសេយ្យមានៈ ( Complexe de supériorité ) ដែលយល់ថា មានតែខ្លួនឯងទេដែលរុងរឿង ថ្លៃថ្នូរលើសអ្នកដទៃ ។

នៅក្នុងរដ្ឋផ្តាច់ការ គ្មានស្នេហាមាតុភូមិទេ ។ ហុលបាច់ ( Holbach : 1723 - 1789 ) ទស្សនៈវិទូបារាំងពោលថា « **ស្នេហាមាតុភូមិអាចមាននៅក្នុងប្រទេសទាំងឡាយណា ដែលពលរដ្ឋមាន សេរីភាព ពិតប្រាកដ ដែលពលរដ្ឋត្រូវគ្រប់គ្រងដោយច្បាប់សមធម៌ (lois équitables) ដែលពលរដ្ឋរីករាយរួបរួមគ្នាជាធ្លុងមួយ . . .** » ។

ដោយ បណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាន**

**លោក វេស៊្យូ យល់ថា « សង្គមមនុស្សមួយដែលប្រកបទៅដោយមនុស្សមិនមានចំណេះដឹង តែមានគុណធម៌ល្អ ប្រសើរថ្លៃថ្លា ជាជាងសង្គមមួយដែលមានតែមនុស្សចេះដឹង តែមិនមានចរិយាធម៌ »**

**" On conçoit encore, dit A. Vessiot, une société composée de gens honnêtes san instruction, mais on ne peut concevoir une société de gens instruits sans moralité "**

# ការយល់ដឹងពីបុណ្យចូលឆ្នាំ

ដកស្រង់ និងសម្រួលតាមអត្ថបទ « អធិប្បាយពីបុណ្យចូលឆ្នាំ » របស់លោក **លី ធាមតេង** ចុះក្នុងលិខិតអក្សរសាស្ត្រ ( ព្រឹត្តិប័ត្រប្រចាំខែ មិនា លេខ ៣ ឆ្នាំ ១៩៨២ របស់មជ្ឈមណ្ឌលឯកសារស្រាវជ្រាវ អរិយធម៌ខ្មែរ (CEDORECK) ) ។

ដោយយល់ឃើញថា ខ្លឹមសារនេះជួយបំភ្លឺគ្រូយើងមួយចំនួន ពីកាលបរិច្ឆេទបុណ្យចូលឆ្នាំនោះ គណៈកម្មាធិការនាយកស.ប.ស.ខ សំរេចជ្រើសរើសយកមកចុះផ្សាយដូចខាងក្រោម ៖

*** * ***

បុណ្យចូលឆ្នាំជាទំនៀមចាស់បូរាណណាស់ គឺថា មានមកជាអង្វែងហើយ រកដានអោយឃើញកំនត់ជាក់ថាក្នុងរជ្ជកាលណាមិនបាន ។ ន័យរបស់បុណ្យនេះមានហេតុផលពីរយ៉ាងគឺ ៖

ក. តាមទំនៀមហោរាសាស្ត្រ គឺជាការកំណត់ពេលផ្តាច់ឆ្នាំ ដើម្បីសំគាល់ថា ក្នុងរយៈ ១២ខែ ត្រូវបញ្ចប់ត្រឹមពេលបុណ្យនេះ ។ ដូច្នេះ បុណ្យនេះជាចង្វាក់អោយដឹងពេលវេលាផុតឆ្នាំចាស់ចូលឆ្នាំថ្មី ។

ខ. តាមផ្លូវចិត្តវិញ ឃើញថា បុណ្យនេះជាបុណ្យសំរាកពីការងារ ដែលមនុស្សយើងរាល់គ្នាធ្វើការហត់នឿយរាល់ៗ ថ្ងៃនោះ តែងតែយ៉ាប់យ៉ឺនណាស់ ។ ហេតុនេះ គោងតែរកពេលណាមួយ បង្កើតជាបុណ្យប្រចាំជាតិ អោយមនុស្សឈប់សំរាកពីកិច្ចការទាំងអស់គ្នា កាត់រកជួបជុំញាតិមិត្ត ធ្វើបុណ្យធ្វើទានម្តងៗ ទៅ ។

ហេតុផលទាំងពីរយ៉ាងនេះ យើងសូមពង្រីកសេចក្តីអោយបានទូលាយបន្តិច ព្រោះរឿងនេះសព្វថ្ងៃបិតនៅក្នុងការឆ្ងល់ពុំទាន់បានច្បាស់លាស់ក្នុងចិត្ត នៃជនទូទៅនៅឡើយ ។

## ១. តាមកំនត់ហោរាសាស្ត្រ

ចំពោះហេតុផលទី ១ ដែលផ្អែកទៅលើហោរាសាស្ត្រនោះ មានសេចក្តីពិស្តារ ទូលំទូលាយណាស់ ព្រោះយើងធ្លាប់ឃើញហោរគន់គូររកថ្ងៃខែចូលឆ្នាំ ទៀងទាត់តែត្រឹមថ្ងៃទី ១៣ រឺ ១៤ ខែមេសារៀងរាល់ឆ្នាំជាដរាប ។ ឯកំនត់ពេលមានចន្ទគ្រាស - សូរ្យគ្រាស ក៏ទៀតទាត់ឥតដែលល្អៀង ។

អ្នកខ្លះយល់ពីហោរាសាស្ត្រ ( Astronomie ) រមែងយល់ច្រឡំថា ហោរាគិតស្មានតាមភាពស្រមៃ រឺតាមសំឡេកគម្រាតែប៉ុណ្ណោះ តែបើអ្នកយល់ច្បាស់គេដឹងថា ហោរាសាស្ត្រពុំមែនជាវិជ្ជាជាន់ទាប ទាយឫក្សជតាតាមតែស្មានៗ គ្មានគោល គ្មានចារីតឡើយ ។ តាមពិតហោរាសាស្ត្រ ជាវិទ្យាសាស្ត្រជាន់ចាស់ដែលជាមេវិជ្ជានៃវិទ្យាសាស្ត្រទំនើបថ្មីនេះ ។ និយាយអោយខ្លីគឺហោរាសាស្ត្រ និយមវិធីគិតលេខទៀងទាត់ធ្វើជាគោល ។

លោក **ពូច អ៊ីម** សរសេរថា ៖ មានពាក្យបរម្បរាថា « ភូតនៅហោរ ចោរនៅជាង » ។ ពាក្យនេះមានមកយូរអង្វែងហើយ តែថាហោរាមានពីរជំពូកផ្សេងពីគ្នាគឺ : ១-ហោរាសាស្ត្រ ២-ហោរាព្រហ្មជាតិ រឺហោរាយាម

យោគ ។ ឯហោរាយាមយោគជាវិជ្ជាសាធារណៈ មានមនុស្សចេះច្រើន ហើយមានឧទាហរណ៍នឹងប្រយោគផ្សំគ្នា បានជាន័យវែងឥតទីបំផុត ឯវិជ្ជាហោរាសាស្ត្រ មានន័យតែពីរ ការកំនត់ថ្ងៃ ខែ ឆ្នាំ ម៉ោង វេលា សករាជ អោយទៀងទាត់ នឹងកំនត់គោចរព្រះអាទិត្យ ព្រះច័ន្ទ ព្រះរាហូ(១) ព្រះកេតុ(២) ។ សេចក្តីនេះ បញ្ជាក់អោយយើងយល់ច្បាស់ថា ដែលហៅថាហោរាសាស្ត្រ ( Astronomie ) នោះពុំមែនជាតម្រាទាយយាមយោគបូរបាច់ មើលជតារាសីស្រីប្រុសទេ គឺប្រាកដជាក្បួនខ្នាតមានលក្ខណ៍គោលមុតមាំ សំរាប់អ្នកប្រាជ្ញក្នុងលោកគិតគូររកពេលវេលា គឺប្រក្រតិទិនទាំងមូលសំរាប់ប្រកបការទាំងពួងអោយត្រឹមត្រូវតាមកំនត់ ។ ក្បួននេះ យកវិធីគិតលេខជាត្រីមុខ ។

ដូច្នេះ អាស្រ័យលើប្រក្រតិទិននៃហោរាសាស្ត្រនេះ កំនត់អោយមានចង្វាក់ត្រឹមត្រូវថា ១សប្តាហ៍មាន ៧ថ្ងៃ ១ខែ មាន ៣០ថ្ងៃ រឺ ២៩ ថ្ងៃ និង១ ឆ្នាំ មាន១២ ខែ ។ កាលណាពេលវេលាប្រព្រឹត្តទៅគ្រប់ ១២ខែ ហើយចាត់ទុកជា ១ឆ្នាំបរិបូរណ៍ ។ តើហោរាសាស្ត្រ កំនត់យកទីបំផុតឆ្នាំនៅត្រង់ណា ? ហើយចាប់ផ្តើមឆ្នាំនៅត្រង់ណា ?

មុននឹងឆ្លើយសំនួរនេះ យើងសូមលោកអ្នកអានចាប់អារម្មណ៍បន្តិចពីលេខរៀងនៃខែទាំង ១២របស់ខ្មែរយើង គឺចាប់ពីមិគសិរលេខ ១ រហូតកត្តិកលេខ ១២ ។ ហេតុបានជាកំនត់ខែមិគសិរជាដំបូងគេ ព្រោះតាមទំនៀមខ្មែរយើង និងទំនៀមជនជាតិអាស៊ីជាច្រើនទៀត កំនត់យករដូវស្រូវអាក់ធ្វើចម្បង គឺជាដំបូងគេ ម្ល៉ោះហើយមិគសិរជាខែដំបូងនៃរដូវច្រូតជាក់ក៏ចាត់ទុកជាខែលេខ ១រហូតមក ។ នេះបើពោលពីរៀងរដូវតាមចន្ទគតិ តែបើពោលពីពេលដាច់ឆ្នាំវិញតាមសុរិយគតិមានន័យផ្សេងទៅទៀត គឺថាក្បួនហោរាសាស្ត្របានរកឃើញផ្កាយដែលនៅជុំវិញផែនដីជាកំនត់ចក្ររាសី គឺដំនើរប្រព្រឹត្តទៅនៃព្រះអាទិត្យ ផ្កាយទាំងនោះមាន ១២ ដែលមានឈ្មោះដោយឡែកៗ ពីគ្នា ។ ក្នុងបណ្តាផ្កាយទាំង ១២ នៅតំរៀបគ្នានោះ ចន្លោះផ្កាយមួយភាគនៅចំទិសបូពិដែលទុកជាទិសច្បង គេអោយឈ្មោះថា « សង្ក្រាន្ត » គឺនៅចំចន្លោះមេសរាសី ( ខែមេសា ) និងមីនរាសី ( មីនា ) ។

អាស្រ័យលើដំនើរព្រះអាទិត្យចរពីផ្កាយមួយទៅផ្កាយមួយអស់រយៈ ១២ខែរួចមក ដល់ចំនុចទិសបូពិដែលហៅថាសង្ក្រាន្តនោះ ។ ឃើញដូច្នោះ ហោរាកំនត់យកត្រង់សង្ក្រាន្តនេះទុកជាពេលចែកឆ្នាំ ព្រោះផុតពីនេះទៅព្រះអាទិត្យត្រូវដើរទៅតាមរាសីដដែលឡើងទៀត ។

ពោលមកនេះយើងឃើញថា « សង្ក្រាន្ត » ឋិតនៅត្រង់មេសរាសី គឺយើងសព្វថ្ងៃហៅថា ខែ « មេសា » ហេតុនេះ អ្នកប្រាជ្ញហោរាសាស្ត្រក៏កំនត់យកខែមេសាតាមដំនើរគោចរនៃព្រះអាទិត្យ សន្មតថា បុណ្យផ្តាច់ឆ្នាំ គឺធ្វើបុណ្យចូលឆ្នាំនេះ ។ យ៉ាងហ្នឹងហើយ បានជាយើងចូលឆ្នាំតែទៅលើខែ មេសាជាកំនត់ទៀងណាស់ ត្រង់ខែចន្ទគតិដែលកំនត់តាមរដូវពុំបានយកដំនើរព្រះអាទិត្យធ្វើជាសំអាងនោះ ហោរាលោកយកជាសំអាងពុំបានឡើយ គឺថាអោយតែកំនត់ផុតដំនើរព្រះអាទិត្យក្នុងមេសរាសី ហើយទោះចំខែចន្ទគតិណាក៏ដោយ គេត្រូវតែចូលឆ្នាំនៅពេលនោះជាប្រាកដ ។ យើងពោលយ៉ាងនេះ នឹងមានមតិមួយឆ្ងល់ថា ៖ បើយើងយកប្រក្រតិទិនសុរិយគតិជាធំដូច្នេះ តើយើងចាំបាច់ទុកថ្ងៃខែតាមចន្ទគតិប្រើធ្វើអ្វី ? ត្រង់នេះសូមបញ្ជាក់ថា ខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយក្នុងការកំនត់ពេលបុណ្យទានពិន័យ

---

(១). រាហូ រឺរាហូអសុរិន្ទ ជាទេវតាព្រះគ្រោះទី ៨ ដែលជាសត្រូវតែងគ្រប រឺបាំង ចាប់ លេបព្រះអាទិត្យ ព្រះចន្ទ : រាហូចាប់ច័ន្ទ ចន្ទគ្រាស សូរ្យគ្រាស ។

(២). កេតុ (កែត) ឈ្មោះផ្កាយប្រចាំរាសីក្នុងនពគ្រោះ ។ ឈ្មោះថ្មមានពន្លឺភ្លឺខ្លាំង ធ្លាក់ចុះពីអាកាសមកលើផែនដី ។

ផ្សេងៗ ក្នុងពុទ្ធឱវាទ សុទ្ធសឹងកំនត់តាមចន្ទគតិទាំងអស់ ។ ហេតុនេះ យើងត្រូវទុកប្រក្រតិទិនចន្ទគតិប្រើស្របជាមួយសុរិយគតិផងដែរ ។

## ២. តាមទំលាប់ប្រពៃណី :

បើគិតតាមទំលាប់ប្រពៃណីវិញ ការបុណ្យទីមួយៗ សុទ្ធសឹងជាការបង្កើតបរិយាកាសសប្បាយលំហែទុក្ខ រីការនឿយហត់ ។ កាលណាមនុស្សធ្វើការ គ្មានចេះសប្បាយសោះ គឺមនុស្សរស់នៅមិនបានស្រួលដែរ តោងតែរកពេលលំហែម្តងៗ ផង ។ បើជួនជាហោរាបានកំនត់ « សង្ក្រាន្ត » ជាកំនត់ផ្តាច់ឆ្នាំ ដូច្នេះទំលាប់ចាស់បុរាណក៏សន្មតគ្នាយកពេលនេះធ្វើជាពិធីបុណ្យមួយអោយអធិកអធមឡើង ។ ហើយបុណ្យនេះពីបុរាណគេធ្វើពេញមួយខែ គឺមុនពេលថ្ងៃកំនត់កន្លះខែ ។ ក្រោយកន្លះខែ ។ ពិធីបុណ្យសោត ក៏មានភាពចំឡែកណាស់ដែរ គឺថារយៈពេលមួយខែនេះ មានការរកកុសលតាមទំលាប់សាសនាខ្លះៗ គ្រាន់ជាឱកាសប្រជុំ ឱកាសគោរពប្រណិប័តន៍ ដល់ចាស់ព្រឹទ្ធាចារ្យប៉ុណ្ណោះ ឯពេលច្រើនបំផុតគឺការលេងល្បែងផ្សេងៗ នោះទៅវិញទេ ដូចជាល្បែងចោលឈូង ទាញព្រ័ត បោះអង្គុញ ច្រៀងប្របកែ លាក់កន្សែង ចាប់កូនខ្លែង រាំស្លឹកព្រ័ត្រ យោលទោង ។ល ។

ចំពោះការលេងល្បែងនេះទៀត គេនិយមលេងតែពួកកំលោះក្រមុំជាភាគច្រើន ឯពួកអ្នកមានប្តីប្រពន្ធហើយទៅលេងជាមួយគេបានតែមួយភ្លែតៗ ទេ គេមិនអោយលេងយូរឡើយ បើនរណាភ្លេចខ្លួន គេនាំគ្នារំលឹក បើរំលឹកហើយនៅតែមិនឈប់ទៀត គេនឹងនាំគ្នាជៀលត្មេះយ៉ាងខ្លាំង ។ តាមប្រសាសន៍លោកឧកញ៉ា **គឹម យីន** ចាងហ្វាងក្រុមគជេន្ទ្រ[១] ដែលជាអ្នកធ្លាប់រៀបចំកម្មវិធីល្បែងផ្សេងៗ ក្នុងព្រះរាជវាំងតាំងពីរាជ្យព្រះករុណាព្រះ **សុវណ្ណកោដ្ឋ**[២] មកនោះ លោកនិយាយថា ទំលាប់ពីដើមតែដល់បុណ្យចូលឆ្នាំហើយ ក្រមុំកំលោះនៃភូមិនីមួយៗ គេប្រមូលផ្តុំគ្នាជាពួក ជាក្រុមហើយ គេកាត់រកពួកក្រុមភូមិណាមួយទៀតធ្វើជាដៃគូ ឧបមាថា ក្រុមភូមិភ្នំពេញ ត្រូវទៅលេងជាមួយនឹងក្រុមភូមិច្បារអំពៅ ។ ដូច្នេះ ដល់ថ្ងៃកំនត់ហើយ ពួកភ្នំពេញក៏ចាប់ចេញដំនើរទាំងហ្វូងទៅ ដែលមានគ្នា ៤០នាក់ រឺ ៥០នាក់ រឺដល់មួយរយនាក់ផងក៏មាន គេនាំគ្នាដើរជាហ្វូង ហើយមានច្រៀងរាំបណ្តើរតាមផ្លូវ តាមចង្វាក់ស្គរកញ្ឆាបុករហូតតាមចង្វាក់ដេ រឺគេហៅថាបុកកំប្រុកៗ ។ លុះទៅដល់ដើមភូមិច្បារអំពៅ អ្នកស្រុកក៏គេនាំគ្នាមកសង់រោងមួយ គ្រាន់តែជាបង្ហា ហើយមានពាងដាក់ទឹកពេញៗ មានអ្នកកាត់សក់នៅទីនោះ កាលណាពួកភ្នំពេញទៅដល់ គេអញ្ជើញអោយចូលលុបលាងខ្លួនស្អាតបាតក្នុងរោងនោះ ហើយមានទឹកគ្រាប់ជីរ បបរស្ករ សំរាប់ជូនពិសាតាមស្ម័គ្រ ។ លុះសព្វគ្រប់ហើយ ទើបបណ្តើរគ្នាចូលទៅក្នុងភូមិ ហើយចាប់ចែកជាក្រុម ជាពួក ប្រកួតល្បែងផ្សេងៗ តាមស្ម័គ្រ មានឈូង ទាញព្រ័ត្រ អង្គុញ ប្រកែជាដើម ។ រយៈពេលលេងនេះ ពុំមានមួយព្រឹក រឺមួយថ្ងៃទេ គឺគេអាចបិតនៅជាមួយគ្នានោះអស់ពេល ៤ - ៥ថ្ងៃ រឺ ៧ថ្ងៃ - ៨ថ្ងៃ តាមតែគេស្ម័គ្រណាត់គ្នាជាមុន ។ ឯត្រង់ពួកភូមិណាត្រូវលើកគ្នាទៅភូមិនោះក៏ស្រេចតែលើការណាត់ ស្រុះស្រួលគ្នាជាមុនដែរ ។

គិតទៅពេលប្រកបពិធីនេះ ត្រូវចំទៅលើពេលខែចេត្រ ដែលឱកាសទំនេររបស់អ្នកស្រុកយើង ដែលសុទ្ធសឹងជា

(១). ស្តេចដំរី : អ្នកដែលជាធំខាងមុខការរក្សាដំរី ( ចៅហ្វាយក្រុមរក្សាដំរីព្រះរាជទ្រព្យ ) ។
(២). កោដ្ឋមាស : ព្រះមរណនាមនៃព្រះបាទសម្តេចព្រះនរោត្តម ។

កសិករ ផុតពីរដូវការងារស្រែចំការរបស់ខ្លួន ។ ឯទំនៀមលេងល្បែងនេះ ក៏បង្កើតអោយមានសេចក្ដីសប្បាយរីករាយអស់រយៈពេលយ៉ាងយូរ ធ្វើអោយបណ្ដាជនយើងធូរស្រាលខ្លួនមួយរយៈកាលដ៏ធំដែរ ។ នេះហើយជាផលប្រយោជន៍នៃបុណ្យចូលឆ្នាំ ។

បើយើងទទួចពោលពីប្រក្រតិទិនខ្មែរវិញ យើងត្រូវតែបញ្ជាក់ថែមទៀតថា ថ្ងៃខែតាមចន្ទគតិដែលកំនត់យកខែមិគសិរជាខែលេខមួយ ត្រូវទុកជាទំនៀមខាងសាសនា ឯថ្ងៃខែតាមសុរិយគតិដែលជាកំនត់ផ្ដាច់ឆ្នាំនៅពេលមេសរាសីគឺខែមេសាទុកជាសង្ក្រាន្តផ្ដាច់ឆ្នាំនោះ ត្រូវទុកជាតម្រាហោរាសាស្ត្រដែលជាកំនត់អន្តរជាតិ ។

សូម្បីប្រទេសបារាំងកាលពីគ.ស ១១០០ ក៏ធ្វើបុណ្យចូលឆ្នាំនៅខែមីនា ( Mars) ដែរ ហើយគេទុកខែមីនាជាខែទី ១នៃសាសនាគ្រិស្ដផង ប៉ុន្តែ ឥលូវគេប្ដូរមកចូលឆ្នាំនៅខែមករាវិញ ដោយគេនិយមតាមរដូវ គឺយករដូវត្រជាក់ធ្វើជាដើមទី ដូចស្រុកយើងយករដូវត្រជាក់ខែមិគសិរជាដើមទីដែរ ។

ឯប្រទេសខ្មែរយើង កាលក្នុងសម័យអង្គរភាគខាងដើម គឺរវាងមុនគ្រិស្ដសតវត្សទី ១២ កាលនោះ គេពុំបានគោរពហោរាសាស្ត្រ ក៏គេកំនត់បុណ្យចូលឆ្នាំនៅខែមិគសិរ តាមប្រក្រតិទិនចន្ទគតិដែរ ប៉ុន្តែចំនេរក្រោយមក ខ្មែរយើងប្ដូរពេលបុណ្យនេះយកតាមកំនត់ហោរាសាស្ត្រវិញផង ហើយជួបជួននឹងពេលបណ្ដាជនខ្មែរយើងបានទំនេរផង ។



## កសាង និង អភិវឌ្ឍបុគ្គលិកលក្ខណៈរបស់កុមារ

(former et développer la personnalité de l'enfant)

ដោយមានសំនូមពរពីលោកគ្រូយើងខ្លះ អោយខ្ញុំអធិប្បាយពីបុគ្គលិកលក្ខណៈរបស់កុមារអោយបានច្បាស់បន្ថែមទៀតទៅលើអត្ថបទរបស់ខ្ញុំ ដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីគ្រូបង្រៀនលេខ ១-១៩៩៥ ក្រោមចំនងជើងថា សមាសភាគនៃការអប់រំនោះ ខ្ញុំក៏បានប្តេជ្ញាចិត្ត ខិតខំប្រមូលផ្តុំចំនេះដឹងទាំងប៉ុន្មាន ដើម្បីចែកជូនបុគ្គលិកសិក្សាយើង ដែលខ្ញុំយល់ថាពិតជានៅមិនច្បាស់នៅឡើយមែន ។ ប៉ុន្តែ មុននឹងអានអត្ថបទថ្មីនេះ ខ្ញុំសូមលោកគ្រូ អ្នកគ្រូអានអត្ថបទស្តីអំពីសមាសភាគនៃការអប់រំជាមុនសិន ព្រោះអត្ថបទថ្មីនេះគ្រាន់តែបំពេញបន្ថែមប៉ុននោះ ។

ជាបឋមខ្ញុំសូមលោកគ្រូ អ្នកគ្រូយល់ពីបញ្ញត្តិកសាង និងអភិវឌ្ឍ ដែលចុះក្នុងកម្មវិធីសិក្សា សិក្សាសង្គមរបស់ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ ៣១ ។

អភិវឌ្ឍ កិ (បា) ចំរើនក្រៃលែង - លូតលាស់ចំរើន

អភិវឌ្ឍន រឺ អភិវឌ្ឍន៍ (ន) សេចក្តីចំរើនក្រៃលែង

(វចនានុក្រមសម្តេច **ជួន ណាត** )

អភិវឌ្ឍន៍បុគ្គលិកលក្ខណៈរបស់កុមារ តើមានន័យដូចម្តេច ?

បុគ្គលិកលក្ខណៈជាអ្វី ? សំដៅទៅលើអ្វី ?

ដើម្បីអោយបានយល់ស៊ីជំរៅ ខ្ញុំសូមជំរាបថា កូនង៉ែតប្រុស - ស្រី នៅពេលកើតចេញពីផ្ទៃម្តាយ វាមានលក្ខណៈពិសេសខ្លះ ៗ មកជាមួយហើយ តែលក្ខណៈពិសេសនោះ កប់នៅក្នុងខ្លួនមើលមិនឃើញ ។ វានឹងបញ្ចេញអោយយើងឃើញ នៅពេលកំពុងលូតលាស់ គឺចាប់តាំងពីកុមារភាព ភាពជំទង់ រហូតដល់ភាពពេញវ័យ ( adulte ) ។

ប្រការនេះមានលក្ខណៈដូចគ្នានឹងដើមឈើស៊ីផ្លែ ។ មុនដំបូង វាបញ្ចេញពន្លក រឺខ្នែង ។ ខ្នែងក្លាយជាផ្កា ។ ផ្កាទៅជាផ្លែ ។ វិទ្យាសាស្រ្តកសិកម្មមានលទ្ធភាពអាចធ្វើអោយបានពន្លកធំ ផ្កាល្អ និងផ្លែធំល្អ ហើយច្រើន ប៉ុន្តែ គេមិនអាចកាត់ដំណាក់កាលនៃការលូតលាស់បានទេ ។

រីឯមនុស្សវិញ ក៏ដូចគ្នាដែរ ពោលគឺកូនង៉ែត កុមារ ជំទង់ ពេញវ័យ តាមលំដាប់ថ្នាក់ពីតូចទៅធំ រឺពីទាបទៅខ្ពស់ ។

ចរិតលក្ខណៈកុមារម្នាក់ៗ មិនដូចគ្នាទេ ។ ការលូតលាស់ធាត់ធំនៃរាងកាយ អាកប្បកិរិយា បញ្ញា ចិត្ត គំនិតខុសប្លែកគ្នាទាំងអស់ ។ ច្បាប់ចិត្តគរុកោសល្យបានប្រាប់ថា នៅពេលកំពុងលូតលាស់របស់កុមារនេះឯងហើយ ដែលលោកគ្រូ អ្នកគ្រូ ត្រូវរកអោយឃើញចរិតលក្ខណៈសិស្សដោយវិធីមិនគំរាមកំហែង ពោលគឺត្រូវគោរពសិស្ស ។ ចរិតលក្ខណៈណាដែលយើងឃើញថាល្អ គឺត្រូវអោយវាលូតលាស់បន្ថែមទៀត ។ រីឯចរិតលក្ខណៈណាដែលឃើញថាឆ្គង មិនស្របតាមច្បាប់សីលធម៌ សង្គម លោកគ្រូ អ្នកគ្រូ ត្រូវតែកែលំអចរិតលក្ខណៈរបស់កុមារមានពីរបែប ៖

១. ចរិតលក្ខណៈមានពីកំណើត ( caractère inné )

២. ចរិតលក្ខណៈបានដោយការកសាង ( caractère acquis )

ចរិតលក្ខណៈទាំងពីរនេះ ត្រូវតែពង្រីកអោយលូតលាស់ល្អជាដរាប ។ នេះហើយដែលហៅថា អភិវឌ្ឍ ( développer ) ។ ចុះបញ្ញត្តិកសាង ( construire ou former ) បានន័យថាដូចម្តេច ?

ក (កិ) តាំងផ្តើម តាំងពីធ្វើ

សាង (កិ) ក. ធ្វើ សង់ អោយកើតឡើង ។

តាមន័យនេះ គឺចាប់សាងអោយរឹងរឹតតែល្អឡើង នូវចរិតលក្ខណៈបានមកពីឪពុកម្តាយ (តំណពូជ) ។ រីឯចរិតលក្ខណៈមិនល្អ ត្រូវតែខិតខំតាមសំរួលអោយវាបានល្អត្រឹមត្រូវ ។ រីឯចរិតលក្ខណៈបានពីការអប់រំ ( caractère acquis ) ក៏ត្រូវតែមានការកសាងជាប្រចាំ កុំអោយបាត់បង់ទៅវិញដោយប្រការណាមួយ ។

ការពន្យល់របស់ខ្ញុំប៉ុននេះ ប្រហែលជាត្រូវបានយល់ជ្រួតជ្រាបបន្តិចហើយ ។ ខ្ញុំសូមលើកឧទាហរណ៍មកបំភ្លឺបន្ថែមទៀត ។ សិស្សម្នាក់មានបញ្ញាពីកំណើត ។ គ្រូសង្កេតឃើញថា សិស្សនេះឆាប់យល់ឆាប់ចាំ ។ សំនួរបញ្ហា រីទាក់ទងនឹងមេរៀនចាស់ និងថ្មី សិស្សអាចឆ្លើយបានល្អទាំងអស់ ។ ប៉ុន្តែ សិស្សនេះជាសិស្សខ្ជិលខ្ជា មិនសូវយកចិត្តទុកដាក់និងថែទាំសៀវភៅ សំអាតសំលៀកបំពាក់ ។ មិនស្តាប់ដំបូន្មានឪពុកម្តាយ ឃើញដូចនេះ តើឪពុកម្តាយ និងគ្រូ ត្រូវពង្រីកចរិតលក្ខណៈណា ? ហើយកែលំអអត្តចរិតណា ? តើវិធីសាស្ត្របែបណាត្រូវយកមកប្រើដើម្បីអោយសិស្សទៅជាសិស្សមានការផ្ចិតផ្ចង់ ( soigneux ) និងគោរពឪពុកម្តាយ ។

សង្គមជាតិចង់បានមនុស្សប្រកបដោយសីលធម៌ជាធំ ( personnalité morale ) កំលាំងចិត្ត បញ្ញា និងឆន្ទៈមោះមុត ចេះធ្វើខ្លួនអោយប្រព្រឹត្តិទៅតាមគន្លងសីលធម៌ ( se bien conduire ) ចេះសំរបសំរួលទៅតាមកាលវេលាក្នុងសង្គមមួយកំនត់ ( s'adapter ) ចេះសហការគ្នាធ្វើការ ( collaborer ) ចេះយកជ័យជំនះលើខ្លួនឯងផ្ទាល់ និងលើអំពើណាដែលនាំទៅរកអបាយមុខ ។

ជាទីបញ្ចប់ នរណាប្រព្រឹត្តបានជាប្រចាំនូវអំពើជាកុសល ជាពលរដ្ឋល្អ និងជាពលករថ្លៃថ្នូរ ស្គាល់តំលៃជាតិ ខិតខំអោយសង្គមជាតិឈានទៅរកវឌ្ឍនភាព នោះគឺជាមនុស្សប្រកបដោយបុគ្គលិកលក្ខណៈល្អប្រសើរ ដែលសង្គមមនុស្សត្រូវការ និងចង់បាន ។

ដោយលោក ឈិន ឌី

## ដំណាក់កាលនៃការអប់រំ និងដំបូន្មានចំពោះឪពុកម្តាយ និង អ្នកអប់រំ ( ត )

**Les étapes de l'éducation et les conseils aux parents et aux éducateurs**

ត ពីទស្សនាវដ្តីលេខ ៥ ទំព័រ ១៦

### II. វ័យជំទង់ ( គរុណវ័យ )

ក្នុងគរុណវ័យមានលក្ខណៈសំគាល់ខាងរូបរាងកាយ ខាងសតិបញ្ញា និងសតិអារម្មណ៍ដូចតទៅ ៖

**១. កាយ :**

ចំពោះការលូតលាស់ខាងផ្លូវកាយ យើងមិនជំរាបវែងឆ្ងាយទេ ព្រោះឪពុកម្តាយ លោកគ្រូ អ្នកគ្រូបានដឹងខ្លះហើយ ។ វ័យនេះ ជាវ័យពេញកំឡោះ ក្រមុំ រឺគឺជាវ័យគ្រប់ការ ។ គេសង្កេតឃើញការលូតលាស់ឆាប់រហ័សប្លែក គឺសំលេងឡើងគ្រាវដូចសំលេងមាន់តក ។ គ្រាប់ពោធ ( pomme d'Adam ) ឡើងធំជាងមុន ។ មានដុះរោមនៅអង្គជាតិបន្តពូជ នៅលើខ្លួនប្រាណចំពោះជំទង់ អ្នកខ្លះដុះពុកមាត់ចង្កា ។ ដកកំពស់ប្លែក ខ្លះមានដងខ្លួនធំធាត់ ខ្លះស្គម ។ ឆ្អឹងដៃជើងលូតវែង ។

នៅពេលកំពុងឡើងខ្លួននេះ ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ គួរណាស់និយាយប្រាប់កូនប្រុសស្រីអោយបានដឹងមុន កុំអោយភ័យបារម្ភ ។ នេះជារូបភាពមួយនៃការអប់រំអំពីភេទ ( éducation sexuelle ) ។ យុវនារីខ្លះ មិនដឹងខ្លួនទៅពេលមានរដូវ យុវជនមិនដឹងខ្លួនទៅពេលមានទឹកកាម ។

ម្យ៉ាងទៀត នៅពេលឆ្អឹងកំពុងលូតលាស់ គួរបំប៉នចំនីអាហារមានជីវជាតិ និងជៀសវាងកុំអោយធ្វើពលកម្មហួសកំលាំង ព្រោះឆាប់ហេវហត់ណាស់ ។

**២. ចិត្ត :**

ដោយរូបរាងកាយរីកលូតលាស់រហ័សយ៉ាងនេះ ចិត្តគំនិតក៏មានការប្លែកខុសធម្មតា ។ នេះគឺមកពីប្រព័ន្ធប្រសាទមានការប្រែប្រួលដូចគ្នានឹងរូបរាងកាយដែរ ។ គឺខុសប្លែកពីកាលនៅវ័យកុមារអាយុ ១០ រឺ ១១ឆ្នាំ ។ ឪពុកម្តាយពិបាកត្រូវចិត្តគេណាស់ គេឆាប់ខឹង និងមានទឹកមុខមិនស្រួលភ្លាម កាលណាឪពុកម្តាយបន្ទោសអ្វីបន្តិចបន្តួច រឺមានមិត្តភ័ក្តិបង្អាប់ពីរឿងអ្វីមួយ ។ ប៉ុន្តែ គេក៏សប្បាយរីករាយចំពោះការសរសើរ ការចាត់ទុកគេជាមនុស្សធំ ។

ការបាត់លំនឹងក្នុងបឋមវ័យជំទង់នេះ ធ្វើអោយជំទង់មានទឹកចិត្តមិនចង់នៅលេងជាមួយប្អូនៗទេ ។ គេមានមិត្តភ័ក្តិរួមថ្នាក់ គេស្តាប់សំដីនរណាម្នាក់ដែលគេគិតក្នុងចិត្តថា ជាអ្នកពូកែមានថ្វីមាត់ ។ គេចូលចិត្តដើរលេងជាមួយអ្នកនោះ ។ ការគ្រប់គ្រងរបស់ឪពុកម្តាយមិនសូវតឹងតែងដូចកាលពីនៅកុមារ គេបញ្ចេញឫកថាអញធំហើយ ។ អញធ្វើនេះធ្វើនោះតាមតែអំពើចិត្ត តែក៏នៅញញើតញញើមខ្លាចក្រែង រឺអន្ទះអន្ទែងចំពោះរឿងអ្វីមួយ ។ គេចង់មានភាពឯករាជ្យ និងសេរី ព្រោះឪពុកម្តាយខ្លះចាត់ទុកខ្លួនគេថា នៅក្មេងនៅឡើយ ។ គេចង់បញ្ជាក់ថា គេធំហើយ គេមិននៅក្មេង

ទៀតទេ ។ គេដឹងថា ខ្លួនគេមានបញ្ហា រឺមិនមានបញ្ហា រៀនមុខវិជ្ជានេះមិនចូល រឺគេចូលចិត្តមុខវិជ្ជានោះ ។ គេច្រើនតែបញ្ចេញទ្រឹស្តីតាមតែក្បួន (dogmatique) ។ ប៉ុន្តែ ជំទង់នៅស្អាក់ស្ទើរមុននឹងហ៊ានសំរេចអ្វីមួយ ។

រីឯនារីជំទង់វិញ ច្រើនមានចិត្តស្រាល ឆាប់ជឿ ឆាប់ស្រលាញ់ ឆាប់ស្អប់ដោយមិនមានលេសអ្វីមួយក៏សឹងមាន ។ ពេលនេះហើយ ជាពេលពិបាកអប់រំ ។ ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ គួរដឹងពីវ័យជំទង់នេះពីដើមដល់ចុង ។ កាលណាយុវជន - នារី មានអាយុពី ១៨ ទៅ២០ឆ្នាំឡើង គេមានលំនឹងចិត្តឡើងវិញ គេមានសំដីសំដៅស្រួលបួលបន្តិច ហើយទៅតាមបុគ្គលម្នាក់ៗ ។ ខ្លះក៏នៅតែមិនស្រួលនៅឡើយ ។

តើឪពុកម្តាយ លោកគ្រូ អ្នកគ្រូ មានភារកិច្ចធ្វើអ្វីខ្លះ ? មុននឹងកំនត់ភារកិច្ច ខ្ញុំសូមអស់លោកជាឪពុកម្តាយជាគ្រូ សង្កេតអាកប្បកិរិយាកូនអោយបានច្បាស់ ។ តើវាមានចរិតដូចម្តេច ព្រោះកូនម្នាក់ៗ មានចរិតមិនដូចគ្នាទេ ។ ការរាប់រៀបគ្រួសៗ ខាងលើនេះ គឺជាករណីទូទៅ ។

**តាមការពិសោធន៍អ្នកអប់រំគ្រូវ ៖**

១. ដឹងអោយបានច្បាស់ពីភាពច្របូលច្របល់ រីកវរនៅក្នុងរាងកាយនៃជំទង់ ដែលធ្វើអោយចិត្តគំនិត អាកប្បកិរិយាប្រែប្រួលជាខ្លាំង ដែលជាហេតុនាំអោយឪពុកម្តាយ លោកគ្រូ អ្នកគ្រូ មិនយល់ពីភាពផ្លាស់ប្តូររាប់រហ័សនេះ ។ បើយល់បានច្បាស់កាលណា ទើបរកថ្នាំបន្សាបបានកាលណោះ គឺមានតែគុណធម៌មួយដែលត្រូវមាន គឺធម៌ខន្តីដែលជាថ្នាំដ៏មានប្រសិទ្ធភាពបំផុត សំរាប់ប្រើនៅពេលវ័យជំទង់ ។ ប៉ុន្តែ យើងជាអ្នកអប់រំ មិនទុកអោយជំទង់ភ្លើតភ្លើនហួសហេតុឡើយ ។ គ្រូបង្គោលនៅសាលាមធ្យមសិក្សា និងឪពុកម្តាយត្រូវតែសហការគ្នារកថ្នាំបន្សាបដោយវិធីត្រជាក់ កុំក្តុងក្តាំងកុំកាច់អោយបាក់ គឺត្រូវពត់សន្សឹមៗ ។ គេនឹងដឹងខ្លួនជាបណ្តើរៗ ព្រោះចិត្តរហ័សដូចរន្ទះ តែងតែមាននៅលើជំទង់ ។ ចាស់ៗ លោកពោលថា វាជាក្មេងឈាមរាវ ។ ប៉ុន្តែ អ្វីដែលលើកក្នុងពេលនេះ មិនមានដូច្នោះទាំងអស់ទេ ព្រោះថាជំទង់ រឺយុវជន យុវនារី មានចរិតខុសៗគ្នា ។ កូនខ្លះស្រួលប្រដៅ និយាយស្តាប់គ្នាបាន ដឹងទុក្ខលំបាករបស់ឪពុកម្តាយមិនទាមទាររកនេះរកនោះទៅតាមចិត្តចំនង់របស់ខ្លួន ដើម្បីអោយបានដូចគេឯង ។ ប៉ុន្តែ ផ្ទុយទៅវិញ មានកូនពិបាកប្រដៅមិនស្តាប់គ្រូបាធ្យាយ និងឪពុកម្តាយ តក់ម៉ក់ព្រងើយកន្តើយ មិនរីករាយ ។ល ។

២. ដឹងអំពីចិត្ត រឺ បុគ្គលរបស់កូន រឺសិស្សានុសិស្ស ។ កូនដែលកើតមកបាននាំយកមកជាមួយនូវបុគ្គលខ្លះតំណពូជពីឪពុកម្តាយ ។ ដូច្នេះ ចាំបាច់ត្រូវជៀសវាងកុំយកកំហឹងទល់កំហល់ព្រោះកូនជាផលិតផលដែលខ្លួនយើងបង្កើតមក ។ ជីវវិទ្យា និងចិត្តគរុវិទ្យា បានអោយយើងដឹងថា បុគ្គល រឺចរិតបុគ្គលមានមកពីតំណពូជ (Hérédité) និងកកើតថ្មីពីបរិយាកាសណ៍ (ambiance) ។ អ្នកអប់រំត្រូវពង្រឹកចរិតល្អ និងពត់ចរិតមិនល្អដោយហ្វឹកហាត់សិស្សអោយមានកំលាំងឆន្ទៈប្រយុទ្ធ ។ លោក **ហ៊ីម៉ាន់** និង **ឡឺសែន** បានចែកចរិតជា ៨ចង្កោម ៖

- អ្នកឆាប់ខឹង ឆាប់រំជួលចិត្ត (nerveux)
- អ្នកមានមនោសញ្ចេតនា (sentimentaux)
- អ្នកឆាប់ខឹង និងមានចិត្តស្រាល (colériques)
- អ្នកជាប់នឹងតណ្ហា « ចំនង់ខ្លាំង » (passionnés)

- អ្នកឆាប់ខឹង ( sanguins )
- អ្នកមិនសូវនិយាយស្ដី ធ្មឹង ( flegmatiques )
- អ្នកមានចរិតទន់ ល្វើយ ( amorphes )
- អ្នកមានចរិតស្លូក ខ្ជិល កន្ដើយ ( apathiques )

( ការបកប្រែពាក្យមិនទាន់បានល្អប្រសើរនៅឡើយទេ ព្រោះពាក្យបារាំងមួយម៉ាត់ខាងលើនេះ ជាចង្កោមមួយ រឺ គ្រួសារមួយមានវត្ថុធាតុផ្សំជាច្រើន )

សព្វថ្ងៃនេះ ចរិតវិទ្យា ( caractériologie ) ជាវិជ្ជាស្បង់មួយថ្មី ដែលគេបញ្ចូលមកក្នុងសាលាគរុកោសល្យ ដើម្បីអោយគ្រូចេះសំគាល់ចរិតកុមារា កុមារី ។

ដូចនេះ ការរៀបរាប់ខាងលើ គ្រាន់តែជាពតិមានប៉ុណ្ណោះ ។ ដើម្បីសិក្សាអោយបានស៊ីជំរៅនោះ ក្រសួងអប់រំ យុវជន និងកីឡា នឹងបញ្ចូលវិទ្យាសាស្ដ្រនេះទៅក្នុងកម្មវិធីសិក្សាគរុកោសល្យទៅអនាគត ។ ចរិតកុមារា កុមារី តែងតែប្រែប្រួលទៅតាមវ័យរបស់វា ។ វ័យដែលឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ ត្រូវតែយកចិត្តទុកដាក់ជាខ្លាំងនោះ គឺវ័យជំទង់នេះឯង ។ គឺពីអាយុ ១២ រហូតដល់ ១៨ឆ្នាំ រឺ ២០ឆ្នាំ ។

## III. ភាពពេញវ័យ

ចិត្តវិទូបានកំនត់ថា កាលណាយុវជន យុវនារីមានការលូតលាស់ផ្នែកសរីរាង្គ និងផ្នែកស្មារតីបានបរិបូរណ៍ហើយនោះ យុវជន យុវនារីមានមនសិការដឹងខុសត្រូវផ្ទាល់ខ្លួន ។ ការហាត់ពត់លត់ដំចរិតអាកប្បកិរិយា ត្រូវតែប្រតិបត្តិដោយខ្លួនឯង ។ ផ្លូវល្អនាំទៅរកសុភមង្គល និងផ្លូវអាក្រក់នាំចុះរណ្ដៅអបាយមុខ ។ យុវជន យុវនារី ត្រូវមានឆន្ទៈមោះមុតជំនះបានគ្រប់ការទោរទន់របស់ចិត្ត ។ ការសិក្សានៅផ្នែកឧត្ដមសិក្សា បានត្រូវបន្ធូរបន្ថយខាងវិន័យ ព្រោះអ្នកគ្រប់គ្រងយល់ថា គេចេះគិតហើយ មានវិចារណញាណគ្រប់គ្រាន់ហើយ ។ ប៉ុន្ដែ តាមការសង្កេត យើងប្រទះឃើញការខ្វះចន្លោះជាច្រើនចំពោះនិស្សិតដែលមិនបានទទួលការអប់រំល្អពីកុមារភាព ។

ជាសរុប ការដឹងពីការលូតលាស់រូបរាងកាយ និងស្មារតី នាំអោយឪពុកម្ដាយ និងលោកគ្រូ អ្នកគ្រូ ធ្វើការអប់រំស្របទៅតាមច្បាប់ធម្មជាតិ ស្របទៅតាមអត្តចរិតនៃកុមារ ។

ការលូតលាស់បានល្អប្រសើរ ល្អ បង្គួរ និង មធ្យម ទាំងផ្នែកសរីរាង្គ និងស្មារតី អាស្រ័យមួយចំនែកធំដោយតំណពូជ ដោយមជ្ឈដ្ឋានទាំងបី ។ មិនទទួលស្គាល់ក្រឹត្យក្រមរីកចំរើននៃការលូតលាស់របស់មនុស្ស គឺជាការខុសឆ្គងមួយរបស់ឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ និងសង្គម ( សាលាបិទមុខ ) ។

ការស្គាល់ចរិតរបស់កុមារ អាចប្រដូចបានទៅនឹងលោកគ្រូពេទ្យ ដែលស្គាល់នូវលក្ខណៈរោគរបស់អ្នកជំងឺ ។ ការអប់រំមានប្រសិទ្ធិភាព អាស្រ័យដោយការដឹងច្បាស់នូវលក្ខណៈចិត្តរបស់កូន រឺ សិស្ស ។

**ដោយ យ៉ង់ ធី**

## ទំនាក់ទំនងរវាងសកម្មភាពគ្រូ និង សកម្មភាពសិស្សនៅក្នុងថ្នាក់រៀន

កាលណានិយាយពីសាលារៀន ត្រូវនិយាយពីការងារបណ្ដុះបណ្ដាល និងការអប់រំ ។ កាលណានិយាយពីការងារបណ្ដុះបណ្ដាល និងការអប់រំ ត្រូវនិយាយពីគរុកោសល្យ ។ ហើយកាលណានិយាយពីគរុកោសល្យ ត្រូវនិយាយពីសកម្មភាពគ្រូ និងសកម្មភាពសិស្ស ។

នៅក្នុងការសិក្សាស្រាវជ្រាវពីវិធីសាស្ត្របង្រៀន បញ្ហាសកម្មភាពគ្រូ និងសកម្មភាពសិស្ស ត្រូវបានចោទ និងដោះស្រាយនៅគ្រប់ពេលវេលា ពីសំណាក់បណ្ឌិតគរុកោសល្យវិទូទាំងឡាយ ។ ឆ្លុះបញ្ចាំងតាមរយៈសកម្មភាពទាំងពីរនេះ គេអាចចាត់ទុកថា ជាវិធីសាស្ត្របង្រៀនអន់ថយ រឺជាវិធីសាស្ត្របង្រៀនទំនើប ហើយថែមទាំងអាចធ្វើការទស្សន៍ទាយ និងធ្វើការវាយតំលៃចំពោះលទ្ធផលនៃការបង្ហាត់បង្រៀនរបស់លោកគ្រូ អ្នកគ្រូបានទៀតផង ។

**តើទំនាក់ទំនងរវាងសកម្មភាពគ្រូ និងសកម្មភាពសិស្សនៅក្នុងថ្នាក់រៀន ត្រូវមានលក្ខណៈដូចម្ដេច ?**

នៅក្នុងថ្នាក់រៀន គឺជាការអនុវត្តវិធីសាស្ត្របង្រៀនដឹកនាំដោយគ្រូបង្រៀន ដើម្បីអោយសិស្សទទួលបាននូវពុទ្ធិ និងកសាងបាននូវបុគ្គលិកលក្ខណៈតាមគោលដៅនៃការអប់រំដែលបានកំនត់ទុក ។ គ្រប់ការអនុវត្តន៍វិធីសាស្ត្របង្រៀនទាំងអស់ ទោះបីពេលមុន ក៏ដូចជាពេលសព្វថ្ងៃ គឺជាការបញ្ចេញសកម្មភាពរបស់គ្រូ រឺសកម្មភាពរបស់សិស្ស ដែលមានតែ ១ ជ្រុង រឺជាសកម្មភាពដែលរួមផ្សំគ្នា ជះឥទ្ធិពលគ្នាទៅវិញទៅមក ។ តែវិធីសាស្ត្របង្រៀនតាមបែបប្រពៃណីភាគច្រើន គេសង្កេតឃើញតែសកម្មភាពគ្រូដែលធ្វើការតែម្នាក់ឯងយ៉ាងមមាញឹក ។ ចំនែកសិស្ស ធ្វើការតិចតួច ហើយមានមុខងារសំខាន់ គឺកត់ត្រាតាម ចាំតាម និងយល់តាមគ្រូ ពោលគឺ លោកគ្រូជាអ្នកចូលជ្រៅទៅក្នុងខ្លឹមសារមេរៀន រួចយកពុទ្ធិដែលខ្លួនទទួលបានមកអោយសិស្ស តាមរយៈការផ្ទេរ រឺការប្រគល់អោយ ដោយសិស្សស្ថិតនៅជាកត្តាអសកម្ម រឺអាចនិយាយថា សកម្មភាពបង្រៀនមានតែមួយជ្រុងប៉ុណ្ណោះ គឺពីគ្រូទៅសិស្ស ។ សកម្មភាពបែបនេះ គឺជាសកម្មភាពដែលអនុវត្តវិធីសាស្ត្រទទួលយក ( méthode réceptive ) ។




វិធីសាស្ត្រទទួលយក ( méthode réceptive ) នេះ ត្រូវបានអនុវត្តតាំងពីយូរយារណាស់មកហើយនៅស្ទើរគ្រប់សាលារៀន ហើយរហូតមកដល់ពេលនេះ វិធីសាស្ត្រនេះ ក៏នៅមានឥទ្ធិពលនៅឡើយ ដែលលោកគ្រូ អ្នកគ្រូយើងមួយចំនួននៅតែយកមកប្រើប្រាស់នៅគ្រប់ការបង្រៀនមេរៀនទាំងអស់ ។ តាមបទពិសោធន៍ឃើញថា វិធីសាស្ត្រទទួលយកដែលយកសកម្មភាពលោកគ្រូ អ្នកគ្រូជាធំ បាននាំមកនូវលទ្ធផលទាបណាស់ ហើយពុទ្ធិដែលសិស្សទទួលបាន ច្រើនជាពុទ្ធិក្លែងក្លាយទៀតផង ។ ដូចនេះ ការបញ្ចូលវិធីសាស្ត្រថ្មីដែលចាត់ទុកថា « សិស្សជាប្រធានវិស័យភាព » រឺ សិស្សជាមជ្ឈមណ្ឌល » ជាការចាំបាច់បំផុតសំរាប់ការបង្ហាត់បង្រៀនសិស្សនៅសាលារៀនកម្ពុជាយើងនាពេលសព្វថ្ងៃនេះ ។ វិធីសាស្ត្រទំនើបថ្មីនេះបានផ្អែកលើទ្រឹស្ដីវិទ្យាសាស្ត្រច្រើនយ៉ាង ដូចជា ចិត្តសាស្ត្រទូទៅ ចិត្តសាស្ត្រសកម្មភាព សង្គមវិទ្យា . . . ។ល ។ និងផ្អែកលើលក្ខណៈនៃមុខវិជ្ជាបង្រៀននីមួយៗ ថែមទៀតផង ។ វិធីសាស្ត្រថ្មីៗ ទាំងឡាយបានបង្ហាញអោយឃើញពីសកម្មភាពគ្រូ និងសកម្មភាពសិស្ស មានទំនាក់ទំនងគ្នាទៅវិញទៅមក ដោយពុំមានសកម្មភាពទោល

តែមួយជ្រុងណាឡើយ ។ ផ្តើមចេញពីខ្លឹមសារមេរៀន គោលបំណងមេរៀន សំទួមពរបណ្តុះបណ្តាល និងសំទួមពរសង្គម ព្រមទាំងផ្អែកលើបុគ្គលិកលក្ខណៈរបស់សិស្ស ដែលជាកម្មវត្ថុនៃការអប់រំ លោកគ្រូត្រូវរៀបចំសកម្មភាពបង្រៀន និងរៀបចំសកម្មភាពរៀនសូត្ររបស់សិស្ស ដើម្បីអោយសិស្សចូលជ្រៅទៅក្នុងមេរៀន និងក្រេបជញ្ជក់ពុទ្ធិពីមេរៀននោះ ។ ដូចនេះ នៅក្នុងថ្នាក់រៀនមួយចាំបាច់ត្រូវអោយសិស្សធ្វើសកម្មភាព មានចលនាខួរក្បាល ត្រិះរិះពិចារណា ផ្តល់យោបល់ សិក្សារៀនសូត្រ . . . ។ ការធ្វើយ៉ាងនេះ ដើម្បីអោយសិស្សទទួលពុទ្ធិដោយខ្លួនឯង និងរីកចំរើនដោយខ្លួនឯង ពោលគឺ ការទទួលយកពុទ្ធិរបស់សិស្សពុំមែនជាការប្រគល់អោយពីលោកគ្រូ រឺពុំមែនជាការផ្ទេរទឹកពីពាងធំទៅពាងតូចឡើយ ។ ក្នុងទ្រឹស្តីគរុកោសល្យទំនើប បានបញ្ជាក់យ៉ាងច្បាស់ថា « **សកម្មភាពគ្រូ ដើម្បីសកម្មភាពសិស្ស** » រឺ « **ផ្តើមចេញពីសិស្ស ដើម្បីសិស្ស** » ដែលមានន័យថា លោកជាអ្នករៀបចំចាត់តាំងសកម្មភាពបង្រៀន ក្នុងគោលបំណងអោយសិស្សធ្វើសកម្មភាពរៀនសូត្រដោយផ្ទាល់ខ្លួន ហើយ « **ផ្តើមចេញពីសិស្ស ដើម្បីសិស្ស** » មានន័យថា លោកគ្រូ អ្នកគ្រូយល់ថា សិស្សជាបុគ្គលមានលក្ខណៈដោយឡែកៗ សិស្សជាកម្មវត្ថុនៃការអប់រំ និងសិស្សជាប្រធានវិស័យភាព រឺសិស្សជាមជ្ឈមណ្ឌលដែលតំរូវអោយលោកគ្រូត្រូវគិតដល់ការកសាងបុគ្គលិកលក្ខណៈរបស់សិស្ស និងគិតដល់សិស្សជាអ្នកធ្វើសកម្មភាព ដើម្បីអោយខ្លួនគេធ្វើសកម្មភាព និងទទួលបានពុទ្ធិពីមេរៀន ។ ចិត្តសាស្ត្រសកម្មភាពបានបញ្ជាក់យ៉ាងច្បាស់ផងដែរថា « **អ្នកទទួលផល និងទទួលពុទ្ធិពិតប្រាកដ គ្មាននរណាក្រៅពីអ្នកធ្វើសកម្មភាព និងធ្វើការត្រិះរិះយ៉ាងម៉ត់ចត់នោះទេ** » ។

សកម្មភាពគ្រូ និងសកម្មភាពសិស្ស ត្រូវមានតុល្យភាពរវាងគ្នា និងគ្នា ហើយបើលោកគ្រូចេះពង្រីកសកម្មភាពសិស្សកាន់តែបានច្រើន គឺកាន់តែល្អ ។ បើសកម្មភាពសិស្សបានចាប់ពី ៧០ % ឡើងទៅ ហើយលោកគ្រូមានតែ ៣០ % រឺចុះក្រោមទៀតនោះ ជាការប្រសើរណាស់ ។ ប៉ុន្តែ ការនិយាយយ៉ាងនេះ ពុំមែនមានន័យថា លោកគ្រូធ្វើការសោះអង្កើយអោយបានតិចបំផុត រួចទុកអោយសិស្សធ្វើសកម្មភាពអោយបានច្រើនតាមអំពើចិត្តនោះទេ ។ តាមពិត សកម្មភាពសិស្សត្រូវនៅក្រោមការដឹកនាំរបស់គ្រូ ដែលមានព្រំខ័ណ្ឌមួយច្បាស់លាស់ សំដៅទៅសំរេចគោលបំណងមេរៀន ។ គេអាចនិយាយថា សកម្មភាពគ្រូ និងសកម្មភាពសិស្ស ជាសកម្មភាពស៊ីចង្វាក់គ្នា ប្រៀបបាន និងវង់ភ្លេងមួយវង់ ដែលលោកគ្រូជាប្រធានក្រុមភ្លេង ហើយសិស្សជាសមាជិកក្រុមភ្លេង ។ ប្រធានក្រុមភ្លេង និងសមាជិកក្រុមភ្លេងទាំងអស់គ្នា សុទ្ធជាអ្នកធ្វើសកម្មភាពលេងភ្លេង បង្កើតបានជាបទភ្លេងដ៏ពិរោះក្បោះក្បាយជូនវន្តំគ្នា ។ ដូចនេះ បើប្រធានក្រុមភ្លេង លេងបទផ្សេង ហើយសមាជិកក្រុមភ្លេងលេងបទផ្សេងទៀត ហើយបើលោកគ្រូធ្វើសកម្មភាពផ្សេង សិស្សនៅក្នុងថ្នាក់ធ្វើសកម្មភាពផ្សេង ពុំស៊ីចង្វាក់គ្នា នោះបទភ្លេងពុំអាចបង្កើតបានជាបទដ៏ពិរោះអ្វីមួយឡើយ ហើយលទ្ធផលនៃការសិក្សា ក៏ពុំបានសំរេចឡើយ ។

គេអាចសង្កេតនូវទំនាក់ទំនងសកម្មភាពគ្រូ និងសកម្មភាពសិស្សដូចតទៅ ៖



**តើទំនាក់ទំនងរវាងសកម្មភាពគ្រូ និងសកម្មភាពសិស្ស បានស្ដែងចេញតាមរូបភាពណាខ្លះ ?**

ក្រោយក្ដាប់បានខ្លឹមសារមេរៀន លោកគ្រូដាក់គោលបំណងមេរៀនអោយបានច្បាស់លាស់ ហើយលោកគ្រូរៀបចំសកម្មភាពបង្រៀន និងរៀនចុះក្នុងសៀវភៅតែងកិច្ចបង្រៀន ។

- សកម្មភាពគ្រូ និងសកម្មភាពសិស្សបានស្ដែងចេញក្នុងការអនុវត្តន៍វិធីសាស្ត្របង្រៀនទំនើបផ្សេងៗ ដែលលោកគ្រូជ្រើសរើសយកមកអនុវត្តក្នុងការបង្ហាត់បង្រៀនលើមេរៀនណាមួយ ។

- លោកគ្រូអាចប្រគល់កិច្ចការអោយសិស្សធ្វើជាបុគ្គល រឺតាមក្រុមតូច រឺក្រុមធំនៅក្នុងថ្នាក់រៀន រឺនៅផ្ទះ រឺអោយស្រាវជ្រាវ រឺសួរពតិមាន រឺកត់ត្រាចំលើយ រឺត្រិះរិះពិចារណា និងផ្ដល់យោបល់ . . . ដើម្បីសំរេចគោលបំណងមេរៀន ។

- លោកគ្រូអាចចោទសួរជាសំនួរផ្សេងៗ ដូចជា សំនួររំលឹក សំនួរបំផុស និងសំនួរចោទបញ្ហា រឺសំនួរលើកបញ្ហា . . . អោយសិស្សត្រិះរិះពិចារណា និងឆ្លើយ រឺប្ដូរយោបល់គ្នា រវាងសិស្ស និងសិស្សជាបុគ្គល រឺរវាងក្រុមសិស្ស និងក្រុមសិស្ស រឺរវាងសិស្ស និងគ្រូដែលពាក់ព័ន្ធនឹងខ្លឹមសារមេរៀនណាមួយ ។

- លោកគ្រូអាចពន្យល់បណ្ដើរ ចោទបញ្ហាបណ្ដើរ អោយសិស្សផ្ដល់យោបល់បណ្ដើរ ដោយផ្អែកលើវិធីសាស្ត្រអនុមានរួម រឺ អនុមានញែក ។

- លោកគ្រូអាចរៀបចំការពិភាក្សាដល់សិស្សក្នុងក្រុមតូច រឺក្រុមធំនៅក្នុងថ្នាក់រៀន ទៅលើបញ្ហានៅក្នុងមេរៀន រឺបញ្ហាសង្គម ។

- លោកគ្រូអាចអោយសិស្សធ្វើការសង្កេត ពិនិត្យ និងផ្ដល់យោបល់ រឺអនុវត្តជាក់ស្ដែងទៅលើការងារណាមួយដែលទាក់ទងនឹងមេរៀន ។

- លោកគ្រូអាចរៀបចំសកម្មភាពតាមរយៈការប្រើប្រាស់សំភារៈឧបទេស ។

- លោកគ្រូរៀបចំសកម្មភាពតាមរយៈល្បែងប្រជាប្រិយ ។

ការរៀបចំសកម្មភាពរបស់លោកគ្រូ នៅមានសកម្មភាពបន្ទាប់បន្សំមួយចំនួនទៀត តាមគំនិតច្នៃប្រឌិតរបស់លោកគ្រូ អ្នកគ្រូម្នាក់ៗ តែគ្រប់សកម្មភាពដែលលោកគ្រូរៀបចំឡើង ពុំត្រូវឃ្លាតឆ្ងាយពីខ្លឹមសារមេរៀន គោលបំណងនៃការអប់រំសមត្ថភាព និងការកសាងលក្ខណៈសម្បត្តិរបស់សិស្សឡើយ ។ គ្រប់សកម្មភាពសិស្ស ត្រូវនៅក្រោមការចាត់តាំងរបស់គ្រូ ហើយជាបណ្ដើរៗ គេនឹងម្ចាស់ការខ្លួនឯងក្នុងការសិក្សាក៏ដូចជាក្នុងការរៀបចំខ្លួន រៀបចំជីភាពរស់នៅ និងម្ចាស់មាតុប្រទេសរបស់គេ ក្រោយគេចេញពីសាលារៀនទៅ ។ ការពង្រីកសកម្មភាពសិស្ស ជាប្រភពដ៏សំខាន់ក្នុងការពង្រីកលទ្ធិប្រជាធិបតេយ្យជាបណ្ដើរៗ ដល់សង្គម ។

រាល់ការបង្រៀនណាដែលមានតែសកម្មភាពគ្រូ ខ្វះសកម្មភាពសិស្ស រឺផ្ដាច់ចេញសកម្មភាពគ្រូ និងសកម្មភាពសិស្ស រឺសកម្មភាពគ្រូ និងសកម្មភាពសិស្សពុំបានផ្សារភ្ជាប់នឹងខ្លឹមសារមេរៀន គឺជាការបង្រៀនពុំត្រឹមត្រូវមានលក្ខណៈអន់ថយ ។

ដោយបណ្ឌិត ឌ សោ

# ធ្វើជាគ្រូបង្រៀន ត្រូវតែរៀនហើយរៀនទៀត

លោក **ហូ តុងហូ** អ្នកចិត្ត - គរុកោសល្យខ្មែរ ដ៏ល្បីល្បាញម្នាក់មានប្រសាសន៍ថា : « កុមារកម្ពុជាជាភារៈជាទីស្រលាញ់បណ្ដូលចិត្តរបស់គ្រួសារ និងជាភារៈមានតំលៃមិនអាចកាត់ថ្លៃបានរបស់ប្រទេសជាតិ ពោលគឺ មិនមែនជាសត្វកណ្ដុរសំរាប់ធ្វើការពិសោធន៍នោះទេ ។ ប្រការនេះ ទាមទារការបណ្ដុះបណ្ដាលគ្រូបង្រៀនអោយបានធួនល្មម » ។ ព្រោះថា : បើគ្មានក្បួនខ្នាតដឹកនាំបានត្រឹមត្រូវ មិនខុសអ្វីពីបុរសម្នាក់ដែលស្វែងរកផ្លូវក្នុងពេលរាត្រីងងឹតសូន្យ **បង្រៀនសិស្សតាមបែបផ្សងព្រេង** ហើយធ្វើអោយខាតពេលវេលាដ៏មានតំលៃរបស់សិស្សានុសិស្ស ។

ក្នុងការអនុវត្តការងារនៅក្នុងសាលារៀន គ្រូថ្មី ទោះបីសាមីខ្លួនមានសម្បទាគរុកោសល្យ និងឆន្ទៈយ៉ាងណាក៏ដោយ ក៏សាមីខ្លួនបានទទួលស្គាល់ថា : សម្បទាគរុកោសល្យដែលខ្លួនបានទទួលការបណ្ដុះបណ្ដាលដំបូងពីសាលាគរុកោសល្យ និងវិក្រឹតការខេត្ត - ក្រុង ពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ រឺពីមហាវិទ្យាល័យគរុកោសល្យ មិនអាចអនុញ្ញាតអោយសាមីខ្លួនដឹកនាំថ្នាក់រៀនបានដោយជោគជ័យសព្វគ្រប់នៅឡើយទេ ពោលគឺទាមទារអោយគ្រូបង្រៀនមានតំរូវការចាំបាច់បន្តការសិក្សាបន្ថែមទៀត ទាំងវប្បធម៌ទូទៅ និងវប្បធម៌វិជ្ជាជីវៈ ។

តើគ្រូបង្រៀនយើង ត្រូវសុក្រឹតការវប្បធម៌ទូទៅយ៉ាងដូចម្ដេចខ្លះ ?

តើគ្រូបង្រៀនយើងត្រូវបណ្ដុះបណ្ដាលបន្តនូវចំនេះវិជ្ជាជីវៈយ៉ាងដូចម្ដេចខ្លះ ដើម្បីឆ្លើយតបនឹងតំរូវការនៃវិស័យអប់រំជាតិ ដែលតែងមានការអភិវឌ្ឍន៍ជាបន្តបន្ទាប់នោះ ?

គ្រូបង្រៀនត្រូវរៀនពីអ្វីដែលខ្លួនត្រូវបង្រៀន និងត្រូវរៀនពីរបៀបបង្រៀន ។

## I. សុក្រឹតការវប្បធម៌ទូទៅ :

គ្រូបង្រៀនយើងត្រូវសុក្រឹតការវប្បធម៌ទូទៅ « Culture générale » បន្ថែមទៀត ព្រោះថាចំនេះវិជ្ជាទាំងឡាយដែលយើងបានទទួល ក្រោយការបណ្ដុះបណ្ដាល ពិតជានៅមានកំរិត ។

ដូចនេះ យើងត្រូវតែសុក្រឹតការវប្បធម៌ទូទៅតាមរយៈការអានសៀវភៅ ដែលទាក់ទងនឹងអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិវិទ្យា វិទ្យាសាស្ត្រ ចិត្ត - គរុកោសល្យរបស់អ្នកនិពន្ធទំនើបនៅលើសកលលោក និងពិភាក្សាដកពិសោធជាមួយអ្នករួមវិជ្ជាជីវៈ ដែលប្រកបដោយគុណសម្បត្តិបច្ចេកទេសខ្ពស់ ។

ក្រៅពីនេះយើងអាច ៖

- តាមដានព្រឹត្តិការណ៍សំខាន់ៗ របស់ជាតិ និងអន្តរជាតិតាមរយៈការអានទស្សនាវដ្ដី កាសែត ការស្ដាប់វិទ្យុ ការមើលទូរទស្សន៍ . . .
- ស្រាវជ្រាវផ្ទាល់ខ្លួនលើមុខវិជ្ជាចាំបាច់ ដែលទាក់ទងនឹងការពង្រីកចំនេះដឹងទូទៅ
- ស្វ័យវិក្រឹតការ ជីវភាសាបរទេស មានបារាំង អង់គ្លេស និងភាសាបរទេសផ្សេងទៀត ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវចំនេះដឹងដែលជាមរតករបស់មនុស្សជាតិ . . .
- ធ្វើដំនើរទស្សនកិច្ចទៅតាមតំបន់វប្បធម៌ តំបន់ទេសចរណ៍ សេដ្ឋកិច្ច . . . ដែលអោយយើងពង្រីកបាននូវបណ្ដាគំនិតដ៏មានប្រយោជន៍ ពោលគឺ : « **មិនមែនកង្កែបនៅក្នុងអណ្ដូង** » នោះឡើយ ។

## II. ការបណ្តុះបណ្តាលបន្តវប្បធម៌វិជ្ជាជីវៈ

គ្រូបង្រៀនត្រូវធ្វើការបណ្តុះបណ្តាលវប្បធម៌វិជ្ជាជីវៈ « Culture professionnelle » ដូចជា ៖

- អាន និងកត់ត្រាជីវប្រវត្តិនៃទស្សនវិទូ គរុវិទូរបស់ជាតិ និងអន្តរជាតិ ដើម្បីអាចដកស្រង់បាននូវទស្សនបទពិសោធដ៏មានតំលៃក្នុងការងារអប់រំ ដើម្បីយកមកអនុវត្តការងារអប់រំប្រចាំថ្ងៃរបស់យើង ។
- អាន និងកត់ត្រាព្រឹត្តិប័ត្រអប់រំ ទស្សនាវដ្តីអប់រំ ទស្សនាវដ្តីគ្រូបង្រៀន សារពត៌មានដែលមានអត្ថបទទាក់ទងនឹងការអប់រំ ជាភាសាជាតិ និងអន្តរជាតិ ជាពិសេសឯកសារដែលផ្សព្វផ្សាយដោយអង្គការផ្សេងៗ ដែលបានមកជួយស្តារ និងលើកកំពស់ខឿនអប់រំកម្ពុជា ។
- សិក្សា និងកត់ត្រាចរន្តចិត្ត - គរុកោសល្យ ដែលតែងតែអភិវឌ្ឍជាបន្តបន្ទាប់ ដើម្បីផ្សារភ្ជាប់នឹងតថភាពអប់រំជាតិ តាមរយៈការអានសៀវភៅ ចិត្ត - គរុកោសល្យថ្មី ៗ ដែលសរសេរដោយអ្នកនិពន្ធជាតិ និអន្តរជាតិ ។ គ្រូត្រូវចេះសំរបការបង្រៀនទៅតាមច្បាប់ចិត្តសាស្ត្រកុមារ ទៅតាមការសង្កេតផ្ទាល់នៃកុមារម្នាក់ៗ នៅក្នុងថ្នាក់រៀន ។
- ចូលរួម សិក្ខាសាលា សន្និសីទគរុកោសល្យ ជីវចលនាគរុកោសល្យ «animations pédagogiques» ដែលអ្នកដឹកនាំអប់រំយល់ថាជាការចាំបាច់ត្រូវតែរៀបចំឡើង ។

ការរៀបចំប្រជុំពិភាក្សាទាំងនេះមានគោលបំនងធំពីរ ៖

ប្រយុទ្ធនឹងភាពនៅដាច់ពីគេ និងការធ្វើតាមទំលាប់ដដែលៗ « lutte contre l'isolement et la routine »

- ទស្សនកិច្ចអប់រំ ដើម្បីដកពិសោធនៅបណ្តាសាលារៀនអភិវឌ្ឍន៍ក្នុងប្រទេស នៅបរទេស ដើម្បីដកពិសោធក្នុងការគ្រប់គ្រង និងដំនើរការសិក្សាអប់រំទូទៅ ។
- ការជួបប្រាស្រ័យទាក់ទងជាមួយមិត្តរួមវិជ្ជាជីវៈ ដោយប្តូរបទពិសោធន៍រវាងគ្នាទៅវិញទៅមក ។
- អំនានសារាចរណែនាំនានារបស់ក្រសួង និងជួយមតិណែនាំរបស់គ្រូឧទ្ទេស អធិការបឋមសិក្សា អធិការបច្ចេកទេស និងមន្ត្រីអប់រំដែលមានសមត្ថភាពកិច្ចផ្សេងៗ ទៀត ។

### ការដឹកនាំថ្នាក់រៀនបានល្អ ៖

**ដឹកនាំថ្នាក់រៀនបានល្អ ៖**

. រៀបចំកិច្ចតែងការបង្រៀនដោយទៀងទាត់ ផ្ចិតផ្ចង់ និងឈ្លាសវៃបំផុត ។ ការជ្រើសរើសលំហាត់ត្រូវធ្វើឡើងដោយហ្មត់ចត់បំផុត ។

. បង្រៀនតាមវិធីសាស្ត្រ ដែលផ្អែកលើទស្សនៈយល់ថា សិស្សជាមជ្ឈមណ្ឌល ដោយចេះពង្រីកតួនាទីសកម្មរបស់សិស្ស ចេះទាក់ទាញអារម្មណ៍សិស្ស ត្រួតពិនិត្យទៀងទាត់ការងារសិស្ស រក្សាវិន័យថ្នាក់រៀនបានល្អ ក្នុងស្មារតីទទួលខុសត្រូវ គោរពបុគ្គលិកលក្ខណៈរបស់សិស្ស ដែលជាប្រធានវិស័យភាពផង និងជាកម្មវត្ថុនៃការអប់រំផង ។

. សិក្សា កុមារម្នាក់ៗ ដើម្បីអភិវឌ្ឍការបង្រៀនជានិច្ចកាល ។

- ពិចារណាទៅលើកិច្ចការដែលខ្លួនបានធ្វើរាល់ថ្ងៃ ។ គ្រូថ្មីត្រូវពិចារណាទៅលើការបង្រៀនរបស់ខ្លួន តើមានអ្វីជាគុណសម្បត្តិ និងមានអ្វីទៀតជាគុណវិបត្តិ ? នេះជាមធ្យោបាយដ៏ល្អឯក ក្នុងការអភិវឌ្ឍន៍សម្បទាគរុកោសល្យរបស់ខ្លួន ។

- កត់ត្រាប្រមូលចងក្រងឯកសារគរុកោសល្យសំខាន់ៗ ដើម្បីជាជំនួយស្មារតីក្នុងការអនុវត្តន៍ការងារប្រចាំថ្ងៃ ដោយជៀសវាងការឆកល្វែង និងតំលាតទាទា ។

- សរសេរបទពិសោធន៍នានាដែលខ្លួនអនុវត្តបានល្អ និងសំនើរផ្សេងៗ ដើម្បីរួមចំនែកអភិវឌ្ឍវិស័យអប់រំជាតិ ។

ការបណ្តុះបណ្តាលបន្តកំរិតវប្បធម៌ វិជ្ជាជីវៈ និងសុក្រឹតការវប្បធម៌ទូទៅនេះ គ្រូបង្រៀនយើងត្រូវចងចាំថា ៖

- គ្រូបង្រៀនត្រូវតែជាមនុស្សចេះដឹង ជាកម្មករខាងបញ្ញា « Travailleur intellectuel » ។ តើមនុស្សល្ងង់បង្រៀនកូនសិស្សរបស់ខ្លួនបានយ៉ាងដូចម្តេច ?
- « ដោយសារកំរិតវប្បធម៌គេខ្ពស់ ទើបការបង្រៀនរបស់គេមានលក្ខណៈងាយស្រួល ។ » « C'est grâce à une instruction supérieuse que l'on s'élève à la simplicité » ។ ប្រភពទឹកត្រូវតែខ្ពស់ជាងក្បាល រ៉ូប៊ីណេ « La source doit être plus haute que la fontaine » ។
- ការបង្រៀន ទោះបីជាចំនេះជាន់ដំបូង សាមញ្ញយ៉ាងណាក៏ដោយ ក៏ទាមទារអោយគ្រូបង្រៀនមានចំនេះដឹងជាក់លាក់ និងទូលំទូលាយដែរ ។ « L'enseignement le plus élémentaire, le plus simple exige au maître des connaissances très sûres et très étendues » ។
- « ត្រូវចេះច្រើនដើម្បីបង្រៀនតិច និងល្អ » « Il faut savoir beaucoup pour enseigner peu et bien »
- ប្រើប្រាស់វិធីសាស្ត្រដែលយល់ថា «សិស្សជាមជ្ឈមណ្ឌល» ច្រើនជាង « គ្រូជាមជ្ឈមណ្ឌល » ។
- គ្រូត្រូវវិលជុំវិញសិស្សមិនមែនសិស្សវិលជុំវិញគ្រូទេ ។ « C'est le maître qui gravite autour de l'élève et non l'élève autour du maître » ។

សរុបមកយើងឃើញថា គ្រូបង្រៀនម្នាក់ៗ ពុំអាចឈប់នៅទ្រឹងមួយកន្លែង ហើយយល់ថា ចំនេះដឹងរបស់ខ្លួនជាការគ្រប់គ្រាន់នោះឡើយ ចាំបាច់ត្រូវតែរៀនហើយរៀនទៀត រៀនជានិច្ច ។ បើពុំនោះទេ គឺមិនខុសពីកង្កែបនៅក្នុងអណ្តូងនោះឡើយ ។

អ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ តាមដានស្វែងយល់ពីការវិវត្តន៍នៃការអនុវត្តន៍កម្មវិធីសិក្សាថ្មី ជាពិសេសអ្នកបង្រៀនផ្ទាល់ ត្រូវស្គាល់កម្មវិធី និងវិធីសាស្ត្របង្រៀនមុខវិជ្ជានីមួយៗ អោយបានច្បាស់លាស់ ។

បើសិនជាយើងមិនបានស្វែងយល់ពីបញ្ហាទាំងនេះទេ យើងដែលជាមន្ត្រីអប់រំ គឺពិតជាក្លាយជាគ្រូបង្រៀនហួសសម័យហើយពិតជាពុំមានសមត្ថភាពដឹកនាំការរៀនសូត្ររបស់សិស្សានុសិស្សយើងអោយបានដល់កោះដល់ត្រើយនោះឡើយ ។

ក្រៅពីការបង្កើនសម្បទាគរុកោសល្យ ស្វ័យក្រឹតការ អាចអោយគ្រូបង្រៀនយើងជៀសវាងបាននូវអំពើអបាយមុខ និងកោសជ្ឋភាពផ្សេងៗ សំរាប់ជាគំរូល្អដល់សិស្សានុសិស្ស និងមហាជនគ្រប់មជ្ឈដ្ឋាន ។ ប្រការនេះ ក៏អាចលើកកិត្យានុភាព វិស័យអប់រំជាតិបានមួយកំរិតដែរ ។

## គ្រូបង្រៀនម្នាក់ គឺជាអ្នកស្រាវជ្រាវម្នាក់

ដោយលោក ប៉ាង សុត
អធិការបឋមសិក្សា អនុប្រធានមន្ទីរ អយក. ព្រៃវែង



# គរុកោសល្យ & ការគ្រប់គ្រង

## ការកែលំអគុណភាពអប់រំនៅបឋមសិក្សា

បទពិសោធន៍របស់ប្រទេសជាច្រើនក្នុងលោក ពិសេសប្រទេសកំពុងអភិវឌ្ឍន៍បង្ហាញអោយឃើញថា វិធានការទាំងឡាយដូចជាការសាងសង់អគារសិក្សា ការបំពាក់សំភារៈបរិក្ខាសិក្សា ការបង្កើនការបោះពុម្ពសៀវភៅសិក្សា ការលើកកំពស់សមត្ថភាពគ្រូតាមរយៈការបណ្តុះបណ្តាលដំបូង និងការបំប៉ន ពុំទាន់ជាល័ក្ខខ័ណ្ឌគ្រប់គ្រាន់ សំរាប់ទិសដៅកែលំអគុណភាពអប់រំនៅបឋមសិក្សានៅឡើយ ចាំបាច់ត្រូវតួបផ្សំនឹងវិធានការមួយចំនួនទៀត ពិសេសការគ្រប់គ្រងសាលាក្រោមកិច្ចចាត់ចែងទទួលខុសត្រូវរបស់នាយកសាលា ។ ព្រោះអ្វី ?

សកម្មភាពបង្រៀន និងរៀន ជាសកម្មភាពជះឥទ្ធិពលទៅមករវាងគ្រូ និងសិស្សនៅក្នុងសាលា ក្នុងថ្នាក់រៀន សំដៅអោយសិស្សទទួលបាននូវពុទ្ធិពីខ្លឹមសារមេរៀន ។ ហើយនេះក៏ជាការ ឆ្លុះបញ្ចាំងជាចំនេះដឹង ចំនេះធ្វើ បំនិនប្រសប់ និងសីលធម៌រស់នៅ ក្រោមការចាត់ចែងដឹកនាំរបស់នាយកសាលា ។ ដូចនេះ វត្តមានទៀងទាត់ ការរៀបចំកិច្ចការបង្រៀន ការគោរពកម្មវិធីសិក្សា និងពេលម៉ោងបង្រៀនរបស់គ្រូ រួមផ្សំនឹងការយកចិត្តទុកដាក់ ចង់ចេះ ចង់ដឹង ចង់យល់ និងឆន្ទៈខិតខំរៀនសូត្ររបស់សិស្ស ជាវិន័យចាំបាច់ដែលមានតែនាយកសាលាម្នាក់គត់ អាចចាត់ចែងរៀបចំដំនើរការប្រក្រតីទាំងនេះបាន ។

វិធានការខាងលើនេះ ត្រូវបានក្រុមការងារនៃវិទ្យាស្ថានអន្តរជាតិ ផ្នែកផែនការអប់រំ ( IIPE ) ទីក្រុងប៉ារីស ធ្វើការសិក្សាស្រាវជ្រាវលើសាលាបឋមសិក្សារដ្ឋ និងឯកជនមួយចំនួនទាំងក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីចង់ដឹងថា តើមានកត្តាអ្វីខ្លះ ដែលបញ្ចាំងអោយការបង្រៀន និងរៀនទទួលលទ្ធផលល្អ ? របាយការណ៍បង្ហាញថា ៖

- តួនាទីរបស់នាយកសាលា គឺជាកូនសោនៃរចនាសម្ព័ន្ធត្រួតពិនិត្យ និងទ្រទ្រង់ដំនើរការរបស់សាលា ដោយប្រសិទ្ធភាព និងទិន្នផលដែលតាមរយៈនេះញុំាងអោយការបង្រៀន និងរៀនទទួលផ្លែផ្កាស្របតាមបំនង ។

- ជាមួយនេះ ទំនាក់ទំនងគ្រូ និងមាតាបិតា ក្នុងន័យធ្វើអោយមាតាបិតាក្លាយជាដៃគូពិតប្រាកដរបស់គ្រូ ជុំវិញការផ្តល់ពត៌មានទៅមក អំពីការសិក្សារបស់សិស្ស និងកូន ។ បទពិសោធន៍នេះ ជាការលើកទឹកចិត្តដល់ទិសដៅបង្រៀន និងរៀន ហើយអាចប្រព្រឹត្តទៅមិនថានៅទីក្រុង រឺនៅជនបទ អាស្រ័យនឹងភាពប៉ិនប្រសប់របស់គ្រូ និងនាយកសាលា ។ ដូចនេះ កត្តាទំនាក់ទំនងផ្តល់ពត៌មានទៅមក រវាងសាលា និងមាតាបិតា ជាគន្លឹះនៃការកែលំអគុណភាពអប់រំ ។

គឺក្នុងន័យនេះហើយ ដែលយើងវាយតំលៃខ្ពស់ ពីកម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជា ហៅថា « **ផាសិច** » របស់សហភាពអឺរ៉ុប ។ តើប៉ាសិចធ្វើសកម្មភាពអ្វីខ្លះ ? មានលទ្ធផលយ៉ាងណា ?

គោលដៅចំបងរបស់ប៉ាសិច គឺកែលំអគុណភាពអប់រំនៅបឋមសិក្សា តាមរយៈកម្មវិធីធំជាមូលដ្ឋាន ៤គឺ ៖

- ការបណ្តុះបណ្តាលគ្រូ
- ការផលិតសំភារៈឧបទេស
- ការពង្រឹងផ្នែកគ្រប់គ្រង និងផែនការ
- ការបំផុសចលនាសាលារៀន សហគមន៍

ដែលអោយជាផ្លែផ្កាល្អ ទាំងទៅលើផ្នែកស្ថាប័ន ផ្នែកបច្ចេកទេសគរុកោសល្យ និងទាំងទៅលើផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

## ផ្នែកស្ថាប័ន

- ធ្វើសកម្មភាពក្នុងទូទាំងប្រទេស
- សហការជាមួយក្រសួង អ.យ.ក ដោយមានការចូលរួមពីគ្រប់ថ្នាក់ កណ្តាល ខេត្ត ស្រុក និងសាលារៀន និងដោយមានការគាំទ្រពីរាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ។
- បង្កើនមនសិការវិជ្ជាជីវៈរបស់គ្រូ
- ផ្តល់ជំនួយបានសមស្របតាមសេចក្តីត្រូវការពិតប្រាកដ
- បង្កើនភាពស្វាហាប់របស់សហគមន៍ ។

ជារួម កម្មវិធីប៉ាសិចបានត្រូវមជ្ឈដ្ឋានជាតិ និងអន្តរជាតិ វាយតំលៃខ្ពស់ ថាជាកម្មវិធីសមស្របនឹងសភាពការណ៍អប់រំ មានប្រសិទ្ធិភាព មានភាពទន់ភ្លន់ ។ តាមរយៈនេះ ប្រជាជនកម្ពុជាបានស្គាល់យ៉ាងទូលំទូលាយអំពីសហភាពអឺរ៉ុប ។

## ផ្នែកបច្ចេកទេសគរុកោសល្យ

- លើកកំពស់សមត្ថភាពគ្រូបឋមសិក្សា ចំនួន 47 800នាក់
- បណ្តុះបណ្តាលគ្រូឧទ្ទេសចំនួន ៨០០នាក់
- លើកកំពស់ល័ក្ខខ័ណ្ឌរៀនសូត្រ និងរស់នៅរបស់គរុសិស្សចំនួន 1 500នាក់ ក្នុង ១ឆ្នាំសិក្សា
- ពង្រឹងការគ្រប់គ្រង និងគរុកោសល្យ ចំពោះនាយកសាលាបឋមសិក្សាចំនួន 5 000នាក់
- ផលិត និងចែកចាយសំភារៈឧបទេស ២លើក ដល់សាលាបឋមសិក្សាចំនួន 5 000សាលា
- និពន្ធ និងរៀបរៀងកម្មវិធី សៀវភៅសិក្សា និងសៀវភៅណែនាំគ្រូផ្នែកសិក្សាសង្គម សំរាប់បឋមសិក្សា ។
- បោះពុម្ព និងចែកផ្សាយកម្មវិធីសៀវភៅសិក្សា និងសៀវភៅណែនាំគ្រូផ្នែកសិក្សាសង្គម និងវិទ្យាសាស្ត្រអនុវត្ត សំរាប់ថ្នាក់ទី ១ និងទី ៦ តាមនិយាមសៀវភៅ ១ក្បាល សំរាប់សិស្សបឋមសិក្សា ២នាក់ ។

- ប្រមូល និងចងក្រងស្ថិតិសិក្សា សំរាប់បឋមសិក្សា
- កែលំអ និងពង្រឹងភារកិច្ចគ្រប់គ្រង និងចងក្រងស្ថិតិបុគ្គលិកសិក្សា
- បំផុសចលនាសាលារៀន - សហគមន៍

ជារួម សមិទ្ធផលទាំងអស់នេះ បាននិងកំពុងរួមចំនែកក្នុងទិសដៅកែលំអគុណភាពអប់រំនៅបឋមសិក្សាយ៉ាងសកម្ម ។ ផ្លែផ្កាបាន និងកំពុងទទួល ហើយនឹងបន្តវែងឆ្ងាយទៅទៀត

## ផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ

- ក្រុមជំនួយបច្ចេកទេសប្រមាណ ២០នាក់ ធ្វើការជាមួយក្រុមការងារជាមន្ត្រីបុគ្គលិកសិក្សា តាំងពីថ្នាក់ក្រសួងរហូតដល់សាលារៀន ប្រមាណ ៣៥០នាក់ ក្រោមរូបភាពធ្វើការជាសមភាគី ។
- សំរាប់ ២ឆ្នាំដំបូង គិតចាប់ពីខែ តុលា ១៩៩៤ ដល់ខែ កញ្ញា ១៩៩៦ ប៉ាសិចបានប្រើប្រាស់ថវិកាអស់ចំនួន 8 899 971 អេគុយ ។
- សំរាប់ ១ឆ្នាំបន្ថែមទៀត គិតចាប់ពីខែ តុលា ១៩៩៦ ដល់ខែ កញ្ញា ១៩៩៧ ប៉ាសិចនឹងប្រើប្រាស់ថវិកាចំនួន 6 700 029 អេគុយ ។

ជារួម ការងាររដ្ឋបាល និងហិរញ្ញវត្ថុរបស់ប៉ាសិច មានតម្លាភាពគួរអោយសរសើរ ។ ជំនួយជាបច្ចេកទេស និងហិរញ្ញវត្ថុមួយភាគធំ ប្រមាណ 80 % បានជាគុណប្រយោជន៍ពិតៗ ដល់វិស័យ អ.យ.ក ។

ជាសន្និដ្ឋាន ចង់កែលំអគុណភាពអប់រំនៅបឋមសិក្សា មានន័យថា ត្រូវមានអគារសិក្សាដោយបំពាក់សំភារៈបរិក្ខារសមស្រប មានសំភារៈគរុកោសល្យចាំបាច់ មានគ្រូប្រកបដោយមនសិការ និងសមត្ថភាពធន់ល្មម ពិសេសការគ្រប់គ្រងដឹកនាំល្អរបស់នាយកសាលា និងការចូលរួមទទួលខុសត្រូវរបស់មាតាបិតា ។

កម្មវិធីប៉ាសិចបាននិងកំពុងឆ្លើយតបគ្រប់ចំនុចនៃចំនោទខាងលើនេះ ក្នុងនោះ ថែមទាំងមានការលើកកំពស់ល័ក្ខខ័ណ្ឌរស់នៅរបស់គ្រូផងដែរ ។ លទ្ធផលដែលកំពុងហុចអោយ គឺគុណភាពអប់រំនៅបឋមសិក្សា បានកែលំអ និងពង្រឹងជាបណ្តើរៗ ។ វាចាំបាច់ត្រូវមានវិនិយោគរបៀបនេះបន្តទៅមធ្យមសិក្សាកំរិត ១ទៀត ដែលពេលនោះ ការអប់រំមូលដ្ឋានត្រូវបានក្លាយជាកាតព្វកិច្ចរបស់ពលរដ្ឋកម្ពុជាគ្រប់រូប ។

ដោយលោក **ស៊ុខ ចាន់ផល**

## ការស្រាវជ្រាវ ច្នៃប្រឌិត ផលិត
### សំភារៈឧបទេសនៅតាមសាលាបឋមសិក្សា

ទោះជាក្នុងម៉ោងបង្រៀនក្ដី ក្រៅម៉ោងបង្រៀនក្ដី វត្តមានសំភារៈឧបទេសមានសារៈសំខាន់ណាស់ព្រោះវា ៖

១. បង្កើតស្ថានភាពល្អនៅក្នុងដំនើរការបង្រៀន និងរៀន
២. បង្កើនសមត្ថភាពសិស្សក្នុងការរុករកអោយឃើញ និងចាប់យកនូវអ្វីដែលខ្លួនត្រូវទទួលពីមេរៀន
៣. ធ្វើអោយមានភាពច្បាស់ប្រាកដ នូវទំនាក់ទំនង រូបមន្ត ទ្រឹស្ដី . . .
៤. អោបក្រសោបសកម្មភាពគ្រូ និងសិស្ស និងសកម្មភាពសិស្ស និងសិស្សអោយកាន់តែមានភាពជិតស្និទ្ធ
៥. បន្ថយការនឿយហត់របស់គ្រូបង្រៀន និងសិស្ស
៦. ផ្ដល់ទំលាប់ល្អក្នុងការបញ្ចេញគំនិតប្រមូលគំនិត និងបង្កើតគំនិតថ្មី
៧. ដឹកនាំសិស្សជាបណ្ដើរៗ ទៅរកផ្លូវនៃការស្រាវជ្រាវ ប្រឌិត ដែលជាផ្លូវសំខាន់ និងចំបងនៃសកម្មភាពវិទ្យាសាស្ត្របច្ចេកទេសជឿនលឿនរបស់មនុស្សជាតិ
៨. អប់រំសោភណភាព

ដូចច្នេះ ក្នុងមុខរបរជាគ្រូបង្រៀន យើងត្រូវតែមានសុទិដ្ឋិនិយម ទទួលយកទំលាប់ក្នុងការស្រាវជ្រាវ ច្នៃប្រឌិត ផលិត និងប្រើប្រាស់សំភារៈឧបទេស ដើម្បីបំរើផលប្រយោជន៍ខ្លួនឯង និងសិស្សដោយប្រសិទ្ធភាព ។

ដើម្បីធ្វើអោយការងារនេះមានប្រសិទ្ធភាព យើងសូមជូនជាវិភាគទានពីរបៃប គឺទ្រឹស្ដីរួមខ្លីៗ និងការអនុវត្តន៍ល្អិតល្អន់ជាបន្តបន្ទាប់ដូចខាងក្រោមនេះ ។

ពីការផ្ដើមគំនិត រហូតដល់ការប្រើប្រាស់ ការងារនេះត្រូវតែឆ្លងកាត់ការស្រាវជ្រាវ ច្នៃប្រឌិត និងផលិតជាចាំបាច់ ។

ការស្រាវជ្រាវ ត្រូវផ្ដើមចេញពីមុខវិជ្ជា កម្មវិធីសិក្សា មេរៀន ( គោលបំនង និងខ្លឹមសារ ) និងវិធីសាស្ត្របង្រៀនដែលជាអ្នកចង្អុល ក៏វិត កំនត់ព្រំដែនស្រាវជ្រាវរបស់យើង ពោលគឺអោយយើងត្រូវដាក់សំនួរ ៖

- ធ្វើអ្វី ? ធ្វើដើម្បីអ្វី ?

នៅពេលដែលយើងឆ្លើយនឹងសំនួរខាងលើបានហើយ បានសេចក្ដីថា យើងបានកំនត់គោលដៅរបស់សំភារៈឧបទេសណាមួយរួចហើយ ។ ការងារបន្តទៅទៀតគឺ ការគិតអំពីលទ្ធភាពក្នុងការបង្កើតដែលឈរលើគោលការណ៍បួនយ៉ាងរួមគ្នាគឺ ៖

១. យថាប្រភេទនៃការប្រើប្រាស់

២. អាចវាស់វែងការស្រាវជ្រាវ ច្នៃប្រឌិត និងផលិតបាន

៣. លក្ខណៈសមហេតុសមផល

៤. អាចកំនត់ពេលបាន ។

បើយើងអាចក្ដាប់បាននូវចំនុចទាំងបួននេះបានហើយ យើងនឹងអាចឆ្លើយតបនឹងសំនួរសព្វគ្រប់បាន

- ធ្វើអ្វី ? ធ្វើដើម្បីអ្វី ? ធ្វើដូចម្ដេច ? ផ្ដើមពីពេលណា បញ្ចប់នៅពេលណា ?

បានសេចក្ដីថា យើងបានរៀបចំផ្លូវធំៗ និងកំនត់នូវទីលានបេបញ្ហាដែលយើងត្រូវស្រាវជ្រាវនោះឯង ។ ដូច្នេះ តើការស្រាវជ្រាវបង្កើតសំភារៈឧបទេស តំរូវអោយយើងសិក្សាទីលានអ្វីខ្លះ ?




រូបខាងលើនេះ ចង្អុលបង្ហាញនូវទីលានសំខាន់ៗ ដែលអ្នកស្រាវជ្រាវត្រូវឆ្លងកាត់ជាចាំបាច់ ដើម្បីឈានទៅដល់គំរោងផលិត ។

## ១. លទ្ធភាពសេដ្ឋកិច្ច

នៅក្នុងលទ្ធភាពសេដ្ឋកិច្ច បញ្ហាសំខាន់ដែលទាក់ទងដល់ការងារស្រាវជ្រាវ គឺវត្ថុធាតុដើមដែលនៅក្នុងនោះ លក្ខណៈពិសេសរបស់មូលដ្ឋានជាទីលានជិតបំផុត សំខាន់បំផុត ដែលយើងត្រូវតែសិក្សា និងអោយតំលៃ ( ប្រភពធនធានវត្ថុធាតុដើម ដែលសំបូរនៅតាមមូលដ្ឋានសាលារៀន ) ។

ជាធម្មតា សំភារៈឧបទេសមួយ មិនដែលទាមទារតែវត្ថុធាតុដើមដាច់ខាតនោះទេ យើងមានលទ្ធភាពច្រើនក្នុងការជ្រើសរើសយកវត្ថុធាតុដើមបែបណាមួយ ក្នុងចំនោមវត្ថុធាតុដើមតិច រឺច្រើន ដើម្បីសំរបសំរួលជាមួយនឹងតំរូវការណាមួយដែលយើងចង់បាន ។

**ឧទាហរណ៍ :**

- **អក្សរចលិត :** វត្ថុធាតុដើមដែលអាចយកមកប្រើបាន មានដូចជា : ក្រដាសកាតុង កាតុងកុងប្លាកេ ក្រដាសឡាំង ស្លឹករុក្ខជាតិ អំបូរគ្នោតមួយចំនួន ក្តារបន្ទះ ក្តារកុងប្លាកេ បន្ទះលោហៈ ( កំប៉ុងផ្សេងៗ ស័ង្កសី ... ) បន្ទះប្លាស្ទិច . . . ។ល ។

- **មាំកែតភូមិវិទ្យា :** ( តំបន់ភ្នំ ខ្ពង់រាប ទំនាប បឹង ទន្លេ សមុទ្រ )

  *វត្ថុធាតុដើម* : ដីឥដ្ឋ ក្រដាស ស៊ីម៉ង់ ប្លាស្ទិច ស្មោរ ម្នាងសិលា ឈើ អាចម៍រណារ . . . ។ល ។

- **ផ្ទាំងគំនូរ :**

  *វត្ថុធាតុដើម* : ក្រដាសកាតុង ក្រណាត់ កាតុងកុងប្លាកេ ក្តារបន្ទះ កុងប្លាកេ បន្ទះលោហៈ . . . ។ល ។

បានជាខ្ញុំនិយាយថា លក្ខណៈពិសេសរបស់មូលដ្ឋានមានសារៈសំខាន់ គឺដោយសារការច្នៃប្រឌិតមានគុណសម្បត្តិ ដូចខាងក្រោម ៖

ក. ឆ្លើយតបនឹងសំណូមពរប្រើប្រាស់បានទាន់ពេល

ខ. មានអត្ថន័យ សន្សំសំចៃ

គ. ងាយស្រួលក្នុងការផលិត

ឃ. មានឥទ្ធិពលទៅលើការអប់រំសិស្សអោយស្គាល់ - យល់

ស្រលាញ់បរិស្ថានសិក្សារ និងមានទំលាប់ក្នុងការទាញយកប្រយោជន៍អំពីបរិស្ថានសិក្សារនេះ ។

យើងត្រូវទឹកឃើញជានិច្ច ថាអ្វីដែលយើងចង់បានពីសំភារៈឧបទេសនោះ គឺគ្មានអ្វីក្រៅពីខ្លឹមសាររបស់វាដែលសំដៅទៅលើការដឹកនាំសិស្សទៅរកស្ថានភាពល្អមួយ ក្នុងការចាប់យកចំនេះដឹងឡើយ ។ ម្យ៉ាងទៀត មានឱកាសយ៉ាងច្រើន ដែលតំរូវអោយយើងប្រើប្រាស់ធនធានដែលសង្គម រឺមូលដ្ឋានមានជាវត្ថុធាតុដើម សំរាប់បង្កើតសំភារៈណាមួយ ។ ធនធានទាំងឡាយបានមកពីប្រភពពីរ គឺធនធានធម្មជាតិ និងផលិតផល ។ ផលិតផលបានផ្តល់នូវធនធានពីរបែបទៀតគឺ ផលិតផលដែលសង្គមកំពុងប្រើ និងផលិតផលដែលគេប្រើរួចហើយ ( សៀវភៅខ្លះថា កាកសំណល់ ប៉ុន្តែខ្ញុំចៀសវាងមិនប្រើពាក្យនោះទេ ) ។

ដូច្នេះការស្រាវជ្រាវវត្ថុធាតុដើម ដោយឈរលើលក្ខណៈពិសេសរបស់មូលដ្ឋាន គឺជាការប្រមូលបែបផ្សេងៗ នៃវត្ថុទាំងនោះ ហើយជ្រើសរើសយកវត្ថុណាមួយដែលឆ្លើយយ៉ាងច្បាស់ទៅនឹងការសន្សំសំចៃថវិកា ។ គឺចំនុចនេះហើយដែលពិភពលោកក្តី ប្រទេសក្នុងតំបន់ក្តី បាននិងកំពុងតែយកចិត្តទុកដាក់ដោយសុទិដ្ឋិនិយម ។ ។

## ២. លទ្ធភាពបច្ចេកទេស

- អ្នកផលិត : ការចាត់ចែងបង្កើតសំភារៈនៅតាមសាលារៀន ខុសប្លែកពីការចាត់ចែងនៅតាមរោងជាងធំៗ

ដោយសារនៅតាមសាលារៀន តំរូវការច្រើនតែមានលក្ខណៈបន្ទាន់ ។ រីឯការគិតទៅលើការបង្កើតសំភារៈងាយៗ ក៏ច្រើនមានលក្ខណៈទូទៅផងដែរ ។

- **ឧបករណ៍ផលិត** : ឧបករណ៍ផលិតទាំងឡាយ វាអាស្រ័យទៅនឹងសំភារៈដែលត្រូវផលិត ។ ការស្រាវជ្រាវទៅលើឧបករណ៍ក្នុងករណីខាងលើពិតជាពុំមានការលំបាកទេ ។

- **បច្ចេកវិទ្យា** : នេះជារឿងសំខាន់បំផុត ដែលអ្នកស្រាវជ្រាវត្រូវតែព្យាយាមដឹង និងរៀន ហើយយកមកប្រើនៅពេលចង់បង្កើតសំភារៈណាមួយដោយងាយស្រួលនោះ ។ ជាធម្មតាណាស់ អ្នកដែលចេះបច្ចេកវិទ្យាច្រើនមុខ មានលទ្ធភាពច្រើនណាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចរបស់គេ យ៉ាងហោចណាស់ក៏គេអាចយកចំនេះដឹងទាំងនេះមកបំរើសំនូមពរផ្ទាល់ខ្លួន ក្នុងលក្ខណៈសន្សំសំចៃដែរ បើមិនបានយកវិជ្ជាណាមួយនោះទៅធ្វើជាមុខរបរ ។ បច្ចេកវិទ្យាដែលមានប្រយោជន៍ដល់យើងក្នុងន័យនេះ គឺបច្ចេកវិទ្យាដែលទាក់ទងនឹងជីវិតរស់នៅក្នុងលក្ខណៈសាមញ្ញនេះឯង ។ ឧទាហរណ៍ : ជំនាងឈើ ជំនាងដែកតូចតាច ការកែច្នៃឬស្សីវល្លិ ផ្តៅ . . . អគ្គិសនីតូចតាច ផ្សា តួរ ចំលាក់ . . . ។ល ។

នៅពេលដែលយើងស្ថិតនៅក្នុងដំណាក់ការដោះស្រាយអោយចេញជាសំភារៈណាមួយ យើងតែងតែយកបច្ចេកវិទ្យាទាំងឡាយមកថ្លឹងថ្លែង ដើម្បីជ្រើសរើសជានិច្ច ។ ឧទាហរណ៍ : ខ្ញុំចង់បង្កើត « សំភារៈធ្វើតេស្ត » មួយ ខ្ញុំត្រូវតែគិតថា តើខ្ញុំត្រូវជ្រើសរើសយកបច្ចេកវិទ្យាណាមកប្រើអោយសមស្របតាមតំរូវការជាក់ស្តែង ។ ខ្ញុំត្រូវប្រើប្រព័ន្ធអេឡិចត្រូនិច ? រឺមួយប្រព័ន្ធចរន្តអគ្គិសនី រឺមួយប្រព័ន្ធមេកានិច ? រឺមួយបញ្ចូលប្រព័ន្ធទាំងបីជាមួយគ្នា ?

នេះវាអាស្រ័យទៅលើតំរូវការជាក់ស្តែងដែលខ្ញុំត្រូវបំពេញ ។ សំនូមពរនោះគឺ សំរាប់ខ្លួនឯង រឺមួយសំរាប់ជាតំរូវដល់សាលារៀន រឺមួយសំរាប់ចែកអោយគ្រូបង្រៀនយកទៅប្រើ ?

សរុបសេចក្តីមក លោកគ្រូ អ្នកគ្រូ គួរតែស្រាវជ្រាវ ( តាមលទ្ធភាព ) អំពីវិជ្ជាបច្ចេកវិទ្យាទាំងឡាយដែលនៅជុំវិញខ្លួនយើង ដើម្បីជាទុនក្នុងការបំរើសំនូមពរខ្លួនឯង គ្រួសារ សង្គម ជាពិសេសការអប់រំនៅតាមសាលារៀននេះឯង ។

ជាចុងក្រោយនេះ ខ្ញុំយល់ថា លោកគ្រូ អ្នកគ្រូនឹងសំរេចនូវគោលធំៗ នៃការបង្កើតសំភារៈឧបទេសណាមួយពុំខាន ។ តែដើម្បីអោយ « គំនិត » ប្រែក្លាយទៅជាសំភារៈជាក់ស្តែងនោះ យើងត្រូវឆ្លងកាត់ដំណាក់កាលចុងក្រោយមួយទៀត គឺគំរោងផលិត និងផលិត ។

**គំរោងផលិត :**

នៅក្នុងកំរិតសាលារៀននេះ ខ្ញុំសូមបញ្ចូលគំរោងផលិត និងគំរោងបង្កើតសំភារៈឧបទេសជាមួយគ្នា និងធ្វើអោយខ្លី ដោយគ្រាន់តែអោយឆ្លើយសំនួរដែលថា :

១. ធ្វើអ្វី ?

២. ធ្វើដើម្បីអ្វី ?

៣. យកអ្វីខ្លះមកធ្វើ ?

៤. ធ្វើដូចម្តេច ?

៥. ប្រើដូចម្តេច ?

យើងឆ្លើយនឹងសំនួរនេះ ដោយបង្កើតជាក្រដាសបច្ចេកទេសមួយសន្លឹកដូចខាងក្រោម ៖

| |
|---|
| ១. ឈ្មោះសំភារៈ .................................................... |
| ២. គោលបំនង និង ពិពណ៌នា : ............................................ |
| ........................................................................... |
| ៣. វត្ថុធាតុដើម និង ឧបករណ៍ផលិត : ...................................... |
| ........................................................................... |
| ........................................................................... |
| ........................................................................... |
| ៤. របៀបផលិត : ......................................................... |
| ........................................................................... |
| ........................................................................... |
| ៥. របៀបប្រើ : .......................................................... |
| ក. គុណសម្បត្តិ : ........................................................ |
| ខ. គុណវិបត្តិ : ......................................................... |

*** បញ្ជាក់ :**

នៅលេខក្រោយ ខ្ញុំនឹងជូនការណែនាំអំពីការផលិតជាក់ស្តែងជាលំអិត និងច្បាស់លាស់បំផុត ។

ដោយលោក **ឈា ឈឿន**

# គូរផែនទីប្រទេសកម្ពុជា

**គោលបំនង :**

- ចង់អោយសិស្សចេះគូរផែនទីព្រះរាជាណាចក្រកម្ពុជា
- ចង់អោយសិស្សស្គាល់បានច្បាស់លាស់ពីរាងរៅ ព្រំប្រទល់ ទីតាំងនៃភ្នំ ទន្លេមេគង្គ បឹងទន្លេសាប ស្ទឹង និងព្រែកធំៗ នៅព្រះរាជាណាចក្រកម្ពុជា ។
- ទីតាំងរាជធានីភ្នំពេញ ខេត្ត ក្រុងនានា រមនីយដ្ឋានប្រវត្តិសាស្ត្រ និងមណ្ឌលទេសចរ ។

**សំភារៈ :**

ដោយប្រើរូបផែនទីដើម ( រូបទី ១ ) លោកគ្រូ អ្នកគ្រូបង្រៀនសិស្សអោយគូរក្រលាការេតាមរូបផែនទីទីមួយនៅលើក្រដាសសៀវភៅ រឺលើក្រដាសផ្សេងទៀត ។ ទំហំក្រលាការេត្រូវពង្រីក រឺ បង្រួមទៅតាមចំនង់ចង់បានផែនទីតូច រឺធំ តែត្រូវរក្សាចំនួនក្រលាការេទាំងអស់នៅដដែល រួចហើយគូសបន្ទាត់ពី A ចុះមក B ។ គូសវិជ្ជកោណ C.D ក្នុងការេទីមួយខាងឆ្វេង និងខាងលើបង្អស់ ។ នៅជ្រុងខាងឆ្វេង បែកខាងក្រោម គូសបន្ទាត់ F.G និងនៅជ្រុងស្តាំ បែកខាងក្រោម គូសបន្ទាត់ H.I ( មើលសន្ទឹកទី ១ភ្ជាប់ ) ។

ជាមួយគ្នានេះ គ្រូត្រូវគូរនៅលើក្រដាសមួយធំ រឺនៅលើក្តារខៀនដោយខ្លួនឯង ដើម្បីរៀនខ្លួនឯងផង បង្រៀនសិស្សផង ។

កាលណាគ្រូ និងសិស្សបានគូរចប់សព្វគ្រប់អស់ហើយ យើងបានគំនូរមួយដូចរូបទី ២ ( ភ្ជាប់ ) ។

**ដំនើរមេរៀន :**

លោកគ្រូ អ្នកគ្រូបានគំនូរផែនទីយ៉ាងដូចនេះហើយ ។ នៅមេរៀនជាបន្តបន្ទាប់ តើលោកគ្រូ អ្នកគ្រូចាប់បង្រៀនគូរពីអ្វីមុន ?

ក្នុងគោលបំនងខាងលើ យើងបានកំនត់ ហើយស្របទៅតាមទ្រឹស្តីគរុកោសល្យ គឺពីស្រួលទៅពិបាក ។ ដូចនេះសូមបង្រៀនគូរពីព្រំប្រទល់ និងឆ្នេរសមុទ្រជាមុន ។ ព្រំប្រទល់ត្រូវគូរជាបន្ទាត់ពងត្រី ។ រីឯឆ្នេរសមុទ្រ ត្រូវគូរជាបន្ទាត់ពេញ បត់បែនទៅតាមគំនូរដោយយកក្រលាការេ និងបន្ទាត់ត្រង់ជាគោល ។

លោកគ្រូពន្យល់ថា គ្រប់គំនូរផែនទីខាងលើ គឺប្រាប់ទិសខាងជើងជាដរាប ត្រូសរសេរជើង រឺដនៅលើផែនទី ។ ចំពោះទិសបីទៀត លោកគ្រូពន្យល់តាមវិធីដូចគ្នា ។

លោកគ្រូ អ្នកគ្រូ បង្រៀនសិស្សគូរបន្ថែមជាហូរហែរ ស្របទៅតាមមេរៀនភូមិវិទ្យានិមួយៗ ដូចជា ភូមិវិទ្យារូបភូមិវិទ្យានយោបាយ ភូមិវិទ្យាសេដ្ឋកិច្ច ។

ដោយ **យ៉ង់ ធី**

រូបទី ១


A
D
ខាងលើ = ខាងជើង
C
I
F
ខាងឆ្វេង = ខាងលិច
ខាងស្តាំ = ខាងកើត
G
H
B
ខាងក្រោម = ខាងត្បូង

រូបទី ២


A
D
C
F
I
G
H
B
ជួរភ្នំដងរែក
អង្គរ
ទន្លេសាប
មេគង្គ
ភ្នំពេញ
ជួរភ្នំក្រវាញ



## លិខិតចំហ *

### ជូនចំពោះបុគ្គលិកសិក្សាទូទាំងព្រះរាជាណាចក្រកម្ពុជា

ខ្ញុំបានទទួលលិខិតឆ្លើយតបពីលោកគ្រូយើងចំនួនតែបួន (៤) នាក់ ចំពោះប្រស្នា : « **ចំនេះដឹងគ្មានសីលធម៌ជាការបំផ្លិចបំផ្លាញខ្លួនឯងតែប៉ុណ្ណោះ** » ដែលបានចុះក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ៤ ទំព័រ ៣៨ ។

១. លោក **ម៉ែន តាល់** គ្រូបង្រៀននៅសាលាបឋមសិក្សាអំពិល ភូមិអំពិល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

២. លោក **ផែខ សឿន** សាស្ត្រាចារ្យនៅវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង

៣. លោក **ចាប យុទណ្ណា** គ្រូមធ្យមសិក្សាកំរិត II នៃវិទ្យាល័យពាមរក៏ ខេត្តព្រៃវែង

៤. លោក **ញិក និស្សិត** លេខាធិការនៃកំរងសាលាសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្ដាល

ខ្ញុំសូមសរសើរដោយស្មោះចំពោះលោកទាំងបួនរូប ដែលបានយកចិត្តទុកដាក់នឹងប្រស្នានេះ ហើយបានឆ្លើយតបវិញ ទោះជាមានការស្ទាក់ស្ទើរចិត្តយ៉ាងណាក៏ដោយ ។

លោកគ្រូ **ញិក និស្សិត** បានបញ្ចេញមតិថា : ( បើសិនជាចំលើយរបស់ខ្ញុំមិនបានត្រូវក៏ដោយ ក៏ខ្ញុំមិនតូចចិត្តដែរព្រោះថា : « **ខុសជាគ្រូនៃត្រូវ** » ) ។ នេះជាសំដីអ្នកចង់ចេះ ចង់ដឹងពិតប្រាកដមែន ។ ខ្ញុំសូមសរសើរហើយសូមរក្សាគំនិតនេះដដែល ។

លោក **ម៉ែន តាល់** ដែលបានផ្ដល់ចំលើយត្រឹមត្រូវឥតខ្ចោះ ត្រូវបានទទួលរង្វាន់លើកទឹកចិត្តជប់ដុល្លា ( 10$US) ។ ចំនែកម្ចាស់លិខិតបីទៀត ដែលមានការឆ្ងល់ពីសេចក្ដីប្រែភាសា បានស្នើសុំសេចក្ដីបំភ្លឺ ។ ខ្ញុំរីករាយណាស់នឹងបំពេញភារកិច្ចនេះ ព្រោះខ្ញុំឃើញសេចក្ដីប្រែប្លែកៗ គ្នាជាច្រើនក្នុងសៀវភៅគរុកោសល្យ ទិទស្សនាវដ្ដីពិសង្គម

ចាស់ ។ ខ្ញុំមិនហ៊ានដោយដាច់ណាត់ថា ការបកប្រែនោះខុសឡើយ ។ យើងគួរតែសាកល្បងពិចារណាជាមួយគ្នាលើខ្លឹមសារនៃល្បះដែលចុះជាប្រស្នានេះ ។

ជាបឋម ខ្ញុំសូមលោកប្អូនប្រមូលអារម្មណ៍តាមដានទូវការអធិប្បាយពន្យល់របស់ខ្ញុំ ។

ល្បះ ( Science sans conscience n'est que ruine de l'âme » សរសេរក្នុងស.ត.ទី ១៦ ដែលជាសតវត្សរ៍នៃកំនើតអក្សរសាស្ត្របារាំង ។

លោក **រ៉ាប៊ីឡេ** ដែលសប្បាយរីករាយនឹងសតវត្សរ៍ថ្មី បានតាក់តែងសៀវភៅមួយនិយាយពីការអប់រំនាសតវត្សរ៍នោះ ។ ក្នុងសៀវភៅនេះ គាត់ប្រឌិតតួអង្គពីរគឺ Gargantua ជាឪពុក និង Pantagruel ជាកូនដែលមានរូបរាងធំមាំ ខុសប្លែកពីមនុស្សដទៃ ។ ឪពុកចង់អោយកូនមានចំនេះដឹងលើគ្រប់វិជ្ជាទាំងអស់ ទោះជាយល់ រឺមិនយល់យ៉ាងណាក៏ដោយ ក៏ត្រូវតែរៀន ។ ប៉ុន្តែនៅទីបញ្ចប់ គាត់ថា កូនអើយ កូនត្រូវមានចំនេះដឹងច្រើនពិតមែនហើយ តែកូនត្រូវមានការដឹងល្អ ដឹងអាក្រក់ ចេះមានធម៌សប្បុរស និងចេះរស់នៅអោយបានសមរម្យក្នុងសហគមន៍មនុស្ស ។

សេចក្តីសង្ខេបរឿងប៉ុននេះ អាចអោយលោកប្អូនយល់បានថា មនុស្សគ្រប់រូបទោះមានចំនេះដឹងជ្រៅជ្រះយ៉ាងណាក៏ដោយ តែមិនមានការដឹងល្អ ដឹងអាក្រក់ ( conscience morale ) ទេនោះ មនុស្សនោះមិនពេញជាមនុស្សឡើយ ( il n'est pas vraiment homme ) ។

ដោយខ្ញុំយល់ដូចនេះ ទើបខ្ញុំបកប្រែល្បះបារាំងនេះតាមន័យថា « ចំនេះដឹងគ្មានសីលធម៌ជាការបំផ្លាញខ្លួនតែប៉ុននោះ » ។ ល្បះនេះ ត្រូវបានរៀនសូត្រកាលខ្ញុំនៅជាគរុនិស្សិត ។ លោកសាស្ត្រាចារ្យបារាំងរបស់ខ្ញុំ ពន្យល់ខ្ញុំទៅតាមន័យនេះ ព្រោះល្បះបារាំងនេះ សរសេរក្នុងភាសាចាស់ជាន់ដើម ( vieux français ) ។

ឥលូវនេះ សូមលោកប្អូនគិតពីសេចក្តីប្រែពាក្យទីមួយៗ ជាមួយខ្ញុំ ។

៩. **La science et les sciences :** វិជ្ជា - វិទ្យា

**La science** : កន្សោមនៃចំនេះដឹងរបស់មនុស្សទៅលើធម្មជាតិ លើមនុស្ស លើសង្គម លើគំនិត ។ល ។ ដែលបានទទួលតៗគ្នា តាមគំហើញនៃធម្មភាពសត្យានុម័តរបស់បាតុភូតទាំងឡាយ ។

**Les sciences** : កន្សោមនៃមុខវិជ្ជា ( Discipline ) ដែលមានការទាក់ទងដល់ចំនេះដឹងនៃមុខវិជ្ជានីមួយៗ ។

ឧ. : **Les sciences physiques** : រូបវិទ្យា

**Les sciences mathématiques** : គណិតវិទ្យា

**Les sciences appliquées** : វិទ្យាសាស្ត្រអនុវត្ត

**Les sciences exactes** : វិទ្យាសាស្ត្រពិត

**Les sciences humaines** : មនុស្សសាស្ត្រ

* សូមពិនិត្យពាក្យ **science** និង **sciences** ។ តើពាក្យនេះមានសេចក្ដីប្រែអោយចំថាដូចម្ដេច ? តាមមតិខ្ញុំ ខ្ញុំប្រែថា វិទ្យា រឺ វិជ្ជា ។ ចំនែកឯសាស្ត្រ ប្រែថា ក្បួន ច្បាប់ គម្ពីរ ។ល ។

**វិទ្យាសាស្ត្រ** : បានសេចក្ដីថា ក្បួនសំរាប់បង្រៀនវិទ្យា រឺវិជ្ជាតែប៉ុននោះ ។

**វិជ្ជា រឺ វិទ្យា** : សេចក្ដីដឹងច្បាស់ ការចេះដឹង ចំនេះស្របគ្នានឹងពាក្យបារាំង Connaissances - savoir - Science

ក្នុងការប្រើសព្វថ្ងៃនេះ យើងបានលឺ បានឃើញ ពាក្យមួយចំនួនធំ ដែលមានសេចក្ដីបកប្រែដូចតទៅនេះ ។ ឧ : វិទ្យាសាស្ត្រសង្គម រឺសង្គមវិទ្យា ( Sciences sociales ) ។ រូបវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា ធម្មជាតិវិទ្យា វិទ្យាសាស្ត្រសេដ្ឋកិច្ច ។ល ។ ដូចនេះ យើងឃើញថា នៅខាងមុខវិជ្ជាអ្វីមួយ គេថាវិទ្យាសាស្ត្រ ។ ប្រសិនបើដាក់នៅក្រោយវិញ គេលុបសាស្ត្រចោល ថ្វីបើពាក្យសាស្ត្រត្រូវជាប់នឹងវិទ្យា ។

២. **La conscience :**

១. សេចក្ដីដឹងខ្លួន រឺ សម្បជញ្ញៈ សតិសម្បជញ្ញៈ គឺស្មារតី និងសេចក្ដីដឹងខ្លួន

ឧ. : បាត់ស្មារតី : Perdre conscience ។ មានស្មារតីឡើងវិញ រឺដឹងខ្លួនឡើងវិញ : Reprendre conscience ។

២. សញ្ចេតនាដែលមនុស្សយកធ្វើជាបង្អែក ដើម្បីវិនិច្ឆ័យចំពោះសីលភាពនៃសកម្មភាពរបស់ខ្លួន (Conscience morale )

ឧ. : បុរសម្នាក់ចេញពីភោជនីយដ្ឋានក្រោយពីបានផឹកស្រាយ៉ាងក្រាស់ក្រែល ។ ចូលមកដល់ក្នុងឡាន គាត់ហាក់ដូចលឺសំលេងអ្វីមួយខ្សឹបប្រាប់គាត់ថា អ្នកមិនត្រូវបើកឡានទេ ព្រោះអ្នកស្រវឹងស្រា ។ ចូរអ្នកដេកក្នុងឡាននេះសិនទៅ ។ ប្រសិនបើអ្នកនោះ មិនស្ដាប់សម្បជញ្ញ ហើយរឹងចចេសធ្វើបំពាននោះ អ្នកនោះនឹងបានទទួលនូវការស្ដីបន្ទោសពីសម្បជញ្ញ គេនឹងមានវិប្បដិសារីដ៏ជូរចត់ គឺការស្ដាយក្រោយទៅលើកំហុសរបស់ខ្លួននៅពេលដែលមានគ្រោះថ្នាក់ ។

គឺនៅក្នុងន័យទី ២ នេះឯងហើយ ដែលខ្ញុំបកពាក្យ Conscience ថាសីលធម៌[១] ។

៣. **L'âme :** ប្រែថា អត្ត (បា) អាត្មន (សំ) អាត្មា ខ្លួន

ឧ. : អត្តឃាតកម្ម អត្តទត្ថភាព អត្តសញ្ញាណ ។

គេអាចប្រែថា ខ្លួន ចិត្ត ព្រលឹង[២]

---

(១). និយមន័យ Conscience morale ក្នុងវចនានុក្រម Nouveau Petit le Robert page 445

(២). សុំអានវចនានុក្រមខ្មែរ ទំព័រ ១៧២៧ និង ១៧២៨

*

* *

មកដល់ត្រឹមនេះ ខ្ញុំមានជំនឿជាក់ថា លោកប្អូនបានយល់ន័យនៃពាក្យក្នុងល្បះ « Science sans conscience n'est que ruine de l'âme » របស់លោក រ៉ាបឺឡេហើយ ។ តើមែនរឺទេ ? សូមសួរបន្ថែម បើនៅមានការឆ្ងល់មិនទាន់ជាច់ស្រេចក្នុងចិត្ត ។

លំដាប់តទៅនេះ ខ្ញុំសូមស្រង់សេចក្ដីប្រែ និងសំនួររបស់លោកប្អូនដូចតទៅ ៖ ( ខ្ញុំមិនបញ្ចេញឈ្មោះឡើយ )

- ស្បង់ខ្វះញាណ នាំអោយវិនាសអាត្មន
- បើយើងប្រែពី Science ទៅចំនេះដឹង រួចចុះ Connaissance ជាអ្វីដែរ ?
- បើយើងប្រែពី Conscience ទៅសីលធម៌ រួចចុះ Morale ជាអ្វីដែរ ?
- តើចំនេះដឹង (ពុទ្ធិ) និងស្បង់ មួយណាទូលំទូលាយជាង ?
- តើសីលធម៌ និង មនសិការ ខុសគ្នា រឺដូចគ្នា ស្រែរគ្នាយ៉ាងម៉េចដែរ ?
- តើវិទ្យាសាស្ត្រ = ស្បង់ដែរទេ ?
- វិទ្យាសាស្ត្រគ្មានមនសិការ គ្រាន់តែវិនាសកម្មនៃអាត្មនប៉ុននោះ ។
- វិទ្យាសាស្ត្រឥតសម្បជញ្ញៈនាំអោយវិនាសអាត្មន ។

ជាទីបញ្ចប់ ក្នុងនាមគណៈកម្មាធិការ នាយកនៃ ស.ប.ស.ខ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះពរដ៏ស្មោះ ដែលលោកប្អូនបានថ្លែងចំពោះគណៈកម្មាធិការនាយក ចំពោះគណៈកម្មការនិពន្ធ ។

យើងខ្ញុំសូមប្រសិទ្ធពរជូនវិញ សូមប្អូនជំនាន់ក្រោយជួយលើកស្ទួយសីលធម៌សង្គមខ្មែរអោយមានពន្លឺឡើងវិញ ។ សូមលោកប្អូនអាន និងធ្វើអត្ថាធិប្បាយលើអត្ថបទទាក់ទងនឹងសីលធម៌ និងតំលៃសីលធម៌ដែលចុះផ្សាយក្នុងទស្សនាវដ្ដីគ្រូបង្រៀន ចាប់ពីលេខដំបូងមក ។

សូមជូនពរ សុខភាពល្អ ដើម្បីជំនះបានគ្រប់ឧបសគ្គ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ជ. គណៈកម្មាធិការនាយក

ប្រធាន

**យ៉ង់ ធី**

# ចំលើយ សំនួរ បញ្ហា
# និង បង្កើនចំនេះដឹងក្នុងទស្សនាវដ្តីគ្រូបង្រៀនលេខ ៥ ទំព័រ ៤៣

យើងខ្ញុំយកសំនួរទាំងពីរនេះមកចោទក្នុងគោលបំនងអោយលោកគ្រូ - អ្នកគ្រូយើងរៀន

១- ត្រិះរិះពិចារណា ( raisonner )

២- វែកញែករកអោយឃើញថា តើសមហេតុសមផលដែររឺទេ ?

៣. បញ្ចេញមតិយោបល់ដោយវាចា រឺតាមសំនេរ

គោលដៅទាំងបីនេះនាំអោយកើតបញ្ញាត្រិះរិះ និងបណ្តុះមនុស្សមិនអោយជឿផ្តេសផ្តាស ប្រាសចាកញាណសីលធម៌ ( sens moral ) និងញាណនយោបាយ[(១)] ( sens politique )

## សំនួរទី ១ :

- តាមខ្ញុំបានដឹងខ្លះៗ កន្លងមក ប្រធានកប៉ាល ( Capitaine ) កាលណាកប៉ាល់របស់ខ្លួនត្រូវខូចខាតដោយប្រការណាមួយ ត្រូវតែឈរនៅលើកប៉ាល់ ហើយស្លាប់នៅលើកប៉ាល់នោះ ។ យើងនាំគ្នាពិចារណាមើលថា តើដោយមូលហេតុអ្វីបានជាប្រធាននេះបញ្ជាអោយកម្មករស្លាប់ជំនួសខ្លួនវិញ ?

**ចំលើយ** : . ពីព្រោះគាត់ចង់រស់ ហើយអោយគេស្លាប់ជំនួសគាត់ ។ នេះជាអំពើកំសាក ថោកទាបបំផុត និងអសីលធម៌ ។

- រីឯកម្មករវិញ តើជាមនុស្សបែណា ? **ចំលើយ** : . គឺជាមនុស្សល្ងង់ខ្លៅ មិនពេញលេញជាមនុស្សផង ។
- អំពើដែលកម្មករនេះបានធ្វើមិនត្រឹមត្រូវទេ មិនក្លាហានទេ ពីព្រោះអ្វី ? **ចំលើយ** : . កម្មករមិនត្រូវគោរពបញ្ជាដោយងងឹតងងល់បែបនេះឡើយ ដោយមិនមានសំជឹតរ៉ាអ្វីមួយមាត់សោះ ។ម្យ៉ាងទៀត កម្មករនេះមិនទាន់ស្គាល់ន័យនៃជីវិតរបស់ខ្លួនជាមនុស្សដែលមានភាតព្វកិច្ចធំពីរ :

១. ជីវភាតព្វកិច្ច ( Obligation biologique )

២. ភាតព្វកិច្ចសង្គម - វប្បធម៌ ( Obligation socio- cuturelle )

( **សូមអានសីលធម៌ និង គោលធម៌ទ្រទ្រង់មនុស្សជាតិ ទំព័រ ២៧ និង ២៨** )

ការសំលាប់ខ្លួនឯងដោយឥតន័យ ជាអំពើឧក្រិដ្ឋ ជាអំពើកំសាក ។

កម្មករនេះ ត្រូវតែលោតចុះទឹក រឺជិះទូករំដោះខ្លួនអោយបានរស់រានមានជីវិតដូចគេឯង ។

## សំនួរទី ២ :

ក្នុងគោលបំនងដដែលដូចខាងលើ ខ្ញុំសូមស្នើចំពោះលោកគ្រូ - អ្នកគ្រូ សូមមានចំនង់ចំនូលចិត្តអានជាប្រចាំ ដើម្បីបង្កើនចំនេះដឹង បង្កើនការត្រិះរិះពិចារណា កុំទុកអោយខួរក្បាលនៅទំនេរឥតប្រយោជន៍ នាំអោយទៅវាលរហោឋាន នៃគំនិត ( Désert spirituel )

---

(១). សម្បជញ្ញៈ ដឹងល្អ និងអាក្រក់ខាងសីលធម៌ និងខាងនយោបាយ

## I. នៅទីក្រុងភ្នំពេញ មានវិថីមួយឈ្មោះថា វិថីព្រះបាទត្រសក់ផ្អែម ។

១. ត្រសក់ផ្អែមជាសម្មតិនាម ។ នាមពិតគឺ **ជ័យ** ។

២. ព្រះបាទត្រសក់ផ្អែមសោយរាជ្យបាន ១៧ឆ្នាំ ហើយសុគតក្នុងជន្មាយុ ៧០ឆ្នាំ គឺនៅឆ្នាំ ១៣០៧ [១] ។

តាមឯកសារ « **មហាបុរសខ្មែរ** » ព្រះបាទត្រសក់ផ្អែមសោយរាជ្យពី គ.ស. ៩៩៨ ដល់ ១០៤៨ គឺបានតែ ៥០ឆ្នាំ [២] ។ តាមសៀវភៅប្រវត្តិវិទ្យារបស់លោក **A. Dauphin Meunier** ព្រះបាទត្រសក់ផ្អែមសោយរាជ្យពី គ.ស ១៣៣៦ ដល់ ១៣៤០ [៣] ( បានតែ ៤ឆ្នាំ ) ។

ដូចនេះយើងឃើញថា ឯកសារទាំងបីនិយាយខុសគ្នាទាំងអស់ ។ ភាពប្រាកដប្រជាមិនមានទាល់តែសោះ ។

នាយត្រសក់ផ្អែមបានឡើងសោយរាជ្យ ដោយបានធ្វើគត់ស្តេចគ្រងរាជ្យដែលបានលួចបេះត្រសក់គាត់នៅក្នុងរាត្រីស្ងាត់ ។ រឿងព្រេងនិទានពីនាយត្រសក់ផ្អែម មានសេចក្តីដំណាលខុសៗគ្នា ប៉ុន្តែស្របគ្នានៅលើបីចំនុច ៖

១. មានបុរសម្នាក់ដាំត្រសក់មានរស់ជាតិផ្អែម បានបេះផ្លែត្រសក់យកទៅថ្វាយស្តេច ហើយបានទទួលលំពែងសំរាប់ការពារចំការត្រសក់របស់ខ្លួន ។

២. បានសំលាប់ស្តេចដោយអចេតនានៅពេលយប់ដោយស្មានថាជាចោរមកលួចផ្លែត្រសក់របស់ខ្លួន ។

៣. បាននាម៉ឺនសព្វមុខមន្ត្រី មូលមតិគ្នាលើកអោយឡើងសោយរាជ្យ ហើយលើកបុត្រីស្តេចអោយជាមហេសីទៀតផង [៤] ។

ព្រះអគ្គមហេសី ព្រះនាម **បុប្ផាទិតី** [៥] ជាបុត្រីនៃស្តេចគ្រងរាជ្យ ។

នាយត្រសក់ផ្អែម ជាជនជាតិសំរែ ។ ប៉ុន្តែ តាមឯកសារ « **មហាបុរសខ្មែរ** » នាយត្រសក់ផ្អែម ជាព្រះរាជបុត្រព្រះបាទចក្រពត្តិរាជ ( ទំព័រ ១០ )

៤. **ជ័យ** ( នាយត្រសក់ផ្អែម ) មានប្អូនប្រុសម្នាក់ឈ្មោះ **សួស** ។ នៅក្នុងរាជ្យព្រះបាទត្រសក់ផ្អែម និងព្រះបាទពញា **សួស** ប្រជារាស្ត្របានសុខសប្បាយ ថ្កើងថ្កានដោយបុណ្យបារមីរបស់ព្រះអង្គពន់ប្រមាណណាស់ ។ សេនាបតី មន្ត្រី រាស្ត្រ ទាំងពួង ឃើញព្រះអង្គមានបុណ្យ មានព្រះជន្មវែងក្រៃលែង លើសជនទាំងពួង ដូច្នោះ ក៏ក្រាបបង្គំទូល សុំព្រះរាជទានព្រះរាជបញ្ញតថា : បើមានមង្គលការអ្វីៗ សូមអោយអ្នកមង្គលការនេះអោយពរថា : **ជ័យហោង សួសហោង** ដើម្បីអោយបានសេចក្តីសុខ និងអាយុយឺនយូរ វែងដូចព្រះអង្គ ។ ព្រះអង្គទ្រង់

---

(១). Adhemard Leclere ទំព័រ ១៤៨

(២). ភាគទី ១ ទំព័រ ៥

(៣). ទំព័រ ៥២

(៤). សូមអានប្រវត្តិសាស្ត្រខ្មែររបស់លោក **ត្រឹង ងា** ទំព័រ ១៧៧ ។

(៥). តាមឯកសារ « **មហាបុរសខ្មែរ** » ។ ប៉ុន្តែ នាមនេះខុសគ្នា និងឯកសាររបស់លោក A. Leclère ។

ព្រះរាជានុញ្ញាតតាមសុំ ។ អាស្រ័យហេតុនេះហើយ បានជាក្នុងមង្គលការទាំងឡាយសព្វថ្ងៃនេះ ជនទាំងពួងតែងអោយពរ គូស្វាមី ភរិយាថ្មីថា **ជ័យហោង សួសហោង** រៀងដរាបមក[(១)] ។

II. គេសង្កេតឃើញថា ក្រោយពីព្រះបាទត្រសក់ផ្អែមបានឡើងសោយរាជ្យ ពាក្យ **ពញា** និង ពាក្យ **អង្គ** ត្រូវបានយកមកប្រើ ដើម្បីហៅព្រះរាជបុត្រ ។ ឧទាហរណ៍ : **ពញាយ៉ាត អង្គនន់ ព្រះអង្គចន្ទ ចៅពញាហុក** ។ ម្យ៉ាងទៀត ចាប់ពីពេលនោះដែរ ពាក្យ **ចរ្វ័ន** ត្រូវបានឈប់ប្រើភ្ជាប់នឹងព្រះនាមស្ដេច ។

ខាងក្រោមនេះ គឺជាការប្រើប្រាស់ពាក្យ **ពញា** ( ដកស្រង់ចេញពីវចនានុក្រមខ្មែរ ទំព័រ ៧២៥ ) **ពញា** ( ញ )ន. ( សៀមប្រើពាក្យនេះជាព្រះយា អ.ថ **ព្រះយ៉ា** ពាក្យសាមញ្ញថា **ផ្យា លាច ពះញា** អ.ថ ផ្យា « **ឧកញ៉ា** » ) ពាក្យ ពញា នេះជាអញ្ញត្រីសព្ទ ពីព្រោះត្រូវសរសេរផ្ញើជើង ញ ជា ញ បែរជាសរសេរវាយតួជា **ពញា** វិញ ដើម្បីកុំអោយច្រឡំ ឮ ( ឮ ឭ ) ។ កាលពីបុរាណព្រេងនាយ ហៅព្រះរាជបុត្រក្សត្រិយ៍ទ្រង់រាជ្យថា **ពញា** ដូចជា **ពញាយ៉ាត ពញាតូ** ជាដើម ។ លុះចំនេរកាលតមក លែងហៅ **ពញា** បែរជាហៅ **អង្គ** វិញដូចជា **អង្គអិម អង្គអេង អង្គនន់ អង្គឌួង** ជាដើម ។ ចំនេរកាលនោះមក ប្រែហៅថា **ព្រះអង្គម្ចាស់** វិញ ដរាបដល់មកសម័យបច្ចុប្បន្ននេះ ។ ក្នុងសម័យបន្ទាប់ពីប្រែ **ពញា** ជា **អង្គ** វិញនោះ ព្រះមហាក្សត្រិយ៍ ទ្រង់យកពាក្យ **ពញា** នេះមកប្រើជា **ថានន្តរ** នៃមន្ត្រីថ្នាក់ខ្ពស់វិញ ប្រើជាបីថ្នាក់គឺ **ពញា ចៅពញា សម្ដេចចៅពញា** ។ លុះចំនេរកាលតពីនោះមកទៀត ប្រើពាក្យ **ឧកញ៉ា អ្នកឧកញ៉ា លោកអ្នកឧកញ៉ា** ជាជំនួសពាក្យ **ពញា** វិញ ដរាបមកដល់សព្វថ្ងៃនេះ ។

សព្វថ្ងៃនេះ ពាក្យ **ពញា** គេឈប់ប្រើហើយ ដោយយកពាក្យ **ឧកញ៉ា** ប្រើជំនួសវិញ ។

ឮ ជាជនជាតិអេស្ប៉ាញឈ្មោះថា **Ruiz de Hernan Gonsales** ។ គាត់បានចូលមកបំរើស្ដេចខ្មែរព្រះនាម **សត្ថា** ។ ព្រះអង្គបានលើកតំកើងគាត់ធ្វើជាអង្គរក្ស ។ គាត់មានមិត្តភក្ដិដ៏ស្និទ្ធស្នាលម្នាក់ ឈ្មោះ **Diogo Veloso** ។ អ្នកនេះបានរៀបអាពាហ៍ពិពាហ៍ជាមួយក្សត្រិយ៍មួយអង្គ ត្រូវជាជីដូនមួយ និងស្ដេចអង្គ **សត្ថា** ។

ព្រះអង្គ **តន់** ជាព្រះរាជបុត្រទី ២ នៃព្រះអង្គ **សត្ថា** បានឡើងសោយរាជ្យហើយបានតែងតាំង **វេឡូសូ** ( Veloso ) ជាចៅហ្វាយខេត្ត បាភ្នំ និង ឮ ( Ruiz ) ជាចៅហ្វាយខេត្ត ត្រាំង ( តាកែវ ) ។

ដោយខ្មែរយើងពិបាកនឹងបញ្ចេញសំលេង **រូអ៊ី** ( Ruiz ) ពេក គេនាំគ្នាហៅថា ឮ ។ ឮ នេះបានឡើងថានន្តរសក្តិជា **ពញា** គឺស្មើនឹង **ឧកញ៉ា** សព្វថ្ងៃ[(២)]

ស្រុក **ពញាឮ** ជាស្រុកដែលយកឈ្មោះ Ruiz មកដាក់ជាប់ពីនោះមក ។

---

(១). ឯកសារ « **មហាបុរសខ្មែរ** » ។ ភាគទី ១ ទំព័រ ៥ សួស រី សួស្ដី ។

(២). Histoire du Cambodge par A.Dauphin Meunier ទំព័រ ៦៨ និង ទំព័រ ១០២

# សំនួរ

( សូមលោកគ្រូ - អ្នកគ្រូ ត្រិះរិះពិចារណារកចំលើយ )

**សំនួរទី ១ :**

លោក **ឈឹម សំនួន** គ្រូបង្រៀនចូលនិវត្តន៍នៅខេត្តកំពត បានតំណាលក្នុងលិខិតរបស់គាត់ ផ្ញើមកគណៈកម្មាធិការនាយក ស.ប.ស.ខ ថា កាលពីឆ្នាំ ១៩៦៧ មានលោកសាស្ត្រាចារ្យម្នាក់នៅអនុវិទ្យាល័យមួយនៅខេត្តកំពត បានបកស្រាយបំភ្លឺសិស្សថា ៖ « **បញ្ញាសជាតក** » មានន័យថា ៖ « **រឿងដែលគេពោលបញ្ជាក់អំពីប្រាជ្ញារបស់ពោធិសត្វមានព្រះមហោសថជាដើម** » ដោយគាត់បកស្រាយសេចក្ដីថា ៖

**បញ្ញា** = ប្រាជ្ញា ។ **ជាតក** = រឿង ។ **ស** = បញ្ជាក់ ដូចមានក្នុងឃ្លាថា ៖

**« សំដីសជាតិ មារយាទសពូជ »** ។

សូមលោកគ្រូ - អ្នកគ្រូ ជួយពិចារណាហើយវិនិច្ឆ័យការបកស្រាយខាងលើនេះ ។

បើការបកស្រាយនេះត្រឹមត្រូវ សូមបញ្ជាក់ថា ត្រឹមត្រូវហើយ ។ ផ្ទុយទៅវិញ ប្រសិនបើការបកស្រាយនេះមិនត្រឹមត្រូវតាមន័យរបស់ពាក្យបាលីទេ សូមកែតំរូវដោយអធិប្បាយវែកញែកបញ្ជាក់ ដើម្បីចុះផ្សាយក្នុងទស្សនាវដ្ដីលេខក្រោយ ។

**សំនួរទី ២ :**

## អំពីប្រាសាទភ្នំជីសូរ

ប្រាសាទភ្នំជីសូរស្ថិតនៅឯណា ? ប្រាសាទនេះ ស្ដេចអង្គណាកសាង ?

ប្រាសាទនេះជ្រុងនីមួយៗ មានប្រវែងប៉ុន្មានម៉ែត្រ ?

នៅជញ្ជាំងខាងក្នុងគុហាធំ គេឃើញមានរូបអ្វីខ្លះ ?

ប្រាសាទសំរាប់មហាក្សត្រក្រសាលស្ថិតនៅខាងណាប្រាសាទធំនោះ ។

## សំនួរទី ៣ :

### មណ្ឌលកំសាន្តមួយបានរៀបចំតំលៃកំសាន្តដូចតទៅ ៖

| ថ្ងៃក្នុងសប្តាហ៍ | តំលៃ | | ប្រមាណវិធី | | |
|---|---|---|---|---|---|
| | មនុស្សចាស់ម្នាក់ | កុមារម្នាក់ | ប្រាក់មាន | ចំនាយ | សល់ |
| ច័ន្ទ | ៧០០៛ | ២៥០៛ | | | |
| អង្គារ | ៨០០៛ | ៣៥០៛ | | | |
| ពុធ | ៥០០៛ | ២០០៛ | | | |
| ព្រហស្បតិ៍ | ៤៥០៛ | ១៥០៛ | | | |
| សុក្រ | ៦០០៛ | ៤០០៛ | | | |
| សៅរ៍ | ៣៥០៛ | ២០០៛ | | | |
| អាទិត្យ | ៦០០៛ | ១៥០៛ | | | |

* លោក «កយ» បានគ្រោងប្រាក់ចំនួន ១ ៥០០៛ សំរាប់ចាយក្នុងសប្តាហ៍ ដើម្បីទៅកំសាន្តនៅទីនោះជាមួយកូនតូចៗ ២នាក់ ។

១. បើគាត់ចង់ទៅកំសាន្តតែ ១ដង ហើយចាយលុយអស់ តើគាត់ទៅកំសាន្តថ្ងៃណា ?

២. បើគាត់ចង់ទៅកំសាន្តតែ ១ដង ហើយសល់លុយ ៣០០៛ តើគាត់ទៅកំសាន្តថ្ងៃណា ?

៣. បើគាត់ចង់ទៅកំសាន្តតែ ១ដង ហើយសល់លុយ ១០០៛ តើគាត់ទៅកំសាន្តថ្ងៃណា ?

៤. បើគាត់ចង់ទៅកំសាន្តតែ ២ដង តើគាត់ទៅកំសាន្តថ្ងៃណា ?

៥. បើគាត់ចង់ទៅកំសានខ្លួនគាត់ ២ដង តែកូនតែ ១ដង តើគាត់ទៅកំសាន្តថ្ងៃណា ?

៦. យោងតាមតំលៃប្រចាំថ្ងៃបែបនេះ តើលោក «កយ» បានទស្សនាគ្រប់ទិដ្ឋភាពដែររឺទេ ?

៧. តើក្នុងមួយខែ លោក «កយ» បានគ្រោងចាយសំរាប់ដើរកំសាន្តអស់ប៉ុន្មាន ?

ដោយលោក **កែច យ៉ារ**

# មេមាន់ខ្មៅមួយ

*កំណាព្យបទពាក្យ ៧*

មេមាន់ខ្មៅមួយប្រឹងយាត្រា
នាំកូនអាត្មាទាំងប្អូនប្រាណ
ស្វែងរកចំនីសព្វទីឋាន
ដើម្បីនឹងបានរស់ជីពជន្ម ។
ដើរដល់ចំការមួយយ៉ាងធំ
សម្ងំកាយដីគ្មានទំរន់
ដើងគេខំកាយភ្នែកគយគន់
ចិន្តាអត់ធន់មិនទៀយណាយ ។
មិនយូរប៉ុន្មានឃើញគ្រាប់ស្រូវ
កប់នៅក្នុងដីសែនសប្បាយ
ទើបប្រឹងស្រែកសួរពីចំងាយ
ដល់សត្វទាំងឡាយមានទាក្ងាន ។
តើនរណាហ្ន៎ដាំគ្រាប់ស្រូវ
តំរូវកប់ដីអោយដុះបាន ?
ទាស្រែកប្រកែកជាមួយក្ងាន
រើយមាន់តិរច្ឆានយើងមិនដឹង ។
គ្រានោះមេមាន់ខ្មៅសាស័ព្ទ
ឆ្លើយប្រាប់ថាខ្ញុំដាំស្រូវហ្នឹង
ដល់ពេលស្រូវទុំនរណាប្រឹង
ប្រមូលផលហ្នឹងដាក់ជង្រុក ?
ពួកក្ងាន និងទានាំគ្នាស្រែក
ប្រកែកមិនព្រមជួយដាក់ទុក
មេមាន់ខ្មៅគិតងឹតមុខ
ប្រឹងធ្វើជង្រុកទុកស្រូវបាន ។
តមកមេមាន់លាន់មាត់ថា
តើមាននរណាចេះប្រមាណ ?
យកស្រូវទៅច្នៃជាម្សៅបាន
ពួកយើងគ្រប់ប្រាណបានធូរស្បើយ ។
ពពួកក្ងានទាវាប្រកែក
នាំគ្នាប្រឹងស្រែកមិនធ្វើឡើយ
មេមាន់ខ្មៅតូចខំឥតស្បើយ
រួចហើយគេច្នៃធ្វើនំប៉័ង ។
ពេលឆ្អិនស្រេចបាច់មេមាន់ខ្មៅ
ចោរោស្រែកសួរលឺខ្លាំងៗ
តើនរណាខ្លះឆីនំប៉័ង
យើងធ្វើសំរាំងឈ្ងុយអស្ចារ្យ ។
ក្ងានទានាំគ្នាស្រែកអឺងកង
ថាឱអ្នកបងខ្ញុំត្រូវការ
ចង់ឆីនំប៉័ងឆ្ងាញ់ពិសា
ព្រោះថាពួកយើងឃ្លានយូរហើយ ។
មេមាន់ខ្មៅតូចខ្ញូចសំដី
ស្រែកថានែវ៉ើកុំផ្ដាសឡើយ
នំឆ្ងាញ់នេះមានតែអញហើយ
និងកូនគ្រាណត្រើយទាំងប្អូនប្រាណ ។
ពួកឯងក្រមខ្ជិលកុំបាច់ឆី
នាំគ្នាលិទ្ធដីទើបឆ្អែតបាន
ចំនែកនំប៉័ងទាំងប៉ុន្មាន
ត្រូវបានពួកយើងឆីឆ្ងាញ់អើយ ។

ដោយលោក **យក់ សំអុន**

# DOTATIONS DU CONCOURS NATIONAL CULTUREL ET SPORTIF INTERCOMMUNAUTES SCOLAIRES DU ROYAUME DU CAMBODGE

organisé par le Ministère de l'Education de la Jeunesse et des Sports
avec le soutien de l'UNION EUROPEENNE
à travers le Programme d'Appui à l'Enseignement Primaire
(PASEC)

* * *

| | |
|---|---|
| **1er Prix Concours Culturel :** | US $ 500 offerts par Leurs Majestés le Roi et la Reine |
| **US $ 4.500** | US $ 4.000 offerts par la BANQUE INDOSUEZ |
| **1er Prix Concours Sportif :** | US $ 500 offerts par Leurs Majestés le Roi et la Reine |
| | US $ 2.000 offerts par la SOCIETE CONCESSIONNAIRE DE L'AEROPORT (SCA) |
| **US $ 4.500** | US $ 2.000 offerts par INDOCHINE INSURANCE UNION |
| **2ème Prix Concours Culturel :** | US $ 300 offerts par Leurs Majestés le Roi et la Reine |
| | US $ 2.000 offerts par ENTERPRISE OIL |
| **US $ 3.000** | US $ 500 offerts par le Centre International d'Etudes Pédagogiques de Sèvres (CIEP) |
| | US $ 200 offerts par GESTETNER |
| **2ème Prix Concours Sportif :** | US $ 300 offerts par Leurs Majestés le Roi et la Reine |
| | US $ 2.000 offerts par KHMER AGENCIES |
| **US $ 3.000** | US $ 500 offerts par le Centre International d'Etudes Pédagogiques de Sèvres (CIEP) |
| | US $ 200 offerts par GESTETNER |
| **3ème Prix Concours Culturel :** | US $ 200 offerts par Leurs Majestés le Roi et la Reine |
| | US $ 1.000 offerts par DUMEZ |
| **US $ 2.500** | US $ 1.000 offerts par DIETHELM TRAVEL |
| | US $ 300 offerts par GESTETNER |
| **3ème Prix Concours Sportif :** | US $ 200 offerts par Leurs Majestés le Roi et la Reine |
| | US $ 1.000 offerts par SOCITEL TELECOM |
| **US $ 2.500** | US $ 500 offerts par TOTAL |
| | US $ 500 offerts par JMK TECHNOLOGIES |
| | US $ 300 offerts par GESTETNER |

# ដំណឹងមរណភាព

គណៈកម្មាធិការនាយកនៃស.ប.ស.ខ សូមជូនពត៌មានថា ៖ ក្នុងរយៈពេលបីខែ បន្តពីខែ មករា - កុម្ភៈ - មិនា ឆ្នាំ១៩៩៧ បន្តពីចុងឆ្នាំ ១៩៩៦ សមាជិក សមាជិកា យើងបានទទួលអនិច្ចកម្មមានកំនើនទាំងអស់ចំនួន : **៨៣ នាក់** ។ រីឯគូស្រករ ( ប្ដី រឺ ប្រពន្ធ ) ចំនួន : **៥៤ នាក់** ដូចតារាងខាងក្រោម ៖

| ល.រ | ឈ្មោះខេត្ត | ចំនួនសព សមាជិក | ល.រ | ឈ្មោះខេត្ត | ចំនួនសព សមាជិក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | មន្ទីរក្រសួងអប់រំយុវជននិងកីឡា | | ១១ | ខេត្ត ស្វាយរៀង | ០៥ នាក់ | |
| ០១ | + អង្គភាពចំណុះ | ០៣ នាក់ | ១២ | ខេត្ត ព្រៃវែង | ០៦ នាក់ | |
| ០២ | ខេត្ត តាកែវ | ០៤ នាក់ | ១៣ | ខេត្ត បាត់ដំបង | ០៥ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ០៨ នាក់ | ១៤ | ខេត្ត កំពង់ឆ្នាំង | ០៤ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ០៥ នាក់ | ១៥ | ខេត្ត កំពង់ស្ពឺ | ០៩នាក់ | |
| ០៥ | ខេត្ត កណ្ដាល | ០៨ នាក់ | ១៦ | រាជធានីភ្នំពេញ | ០៤ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ១២ នាក់ | ១៧ | ខេត្ត ពោធិសាត់ | ០១ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៣ នាក់ | ១៨ | ខេត្ត ស្ទឹងត្រែង | ០២ នាក់ | |
| ០៨ | ខេត្ត កំពត | ០២ នាក់ | ១៩ | ខេត្ត កោះកុង | ០០ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០១ នាក់ | ២០ | ខេត្ត រតនគិរី | ០០ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០០ នាក់ | ២១ | ខេត្ត មណ្ឌលគិរី | ០០ នាក់ | |
| | | សរុប : | | | **៨៣ នាក់** | |

| ល.រ | ឈ្មោះខេត្ត | ចំនួនសពគ្រួសារ ប្ដី រឺ ប្រពន្ធ | ល.រ | ឈ្មោះខេត្ត | ចំនួនសពគ្រួសារ ប្ដី រឺ ប្រពន្ធ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | មន្ទីរក្រសួងអប់រំ យុវជន និងកីឡា | | ១១ | ខេត្ត ស្វាយរៀង | ០៦ នាក់ | |
| ០១ | + អង្គភាពចំណុះ | ០២ នាក់ | ១២ | ខេត្ត ព្រៃវែង | ០៤ នាក់ | |
| ០២ | ខេត្ត តាកែវ | ០២នាក់ | ១៣ | ខេត្ត បាត់ដំបង | ០២ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ០២ នាក់ | ១៤ | ខេត្ត ព្រះវិហារ | ០១ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ០២ នាក់ | ១៥ | ខេត្ត កំពង់ឆ្នាំង | ០២នាក់ | |
| ០៥ | ខេត្ត កណ្ដាល | ០៣ នាក់ | ១៦ | ខេត្ត កំពង់ស្ពឺ | ០៤ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ០៩ នាក់ | ១៧ | រាជធានីភ្នំពេញ | ០៥ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៣ នាក់ | ១៨ | ខេត្ត ពោធិសាត់ | ០១ នាក់ | |
| ០៨ | ខេត្ត កំពត | ០២ នាក់ | ១៩ | ខេត្ត ស្ទឹងត្រែង | ០០ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០១ នាក់ | ២០ | ខេត្ត កោះកុង | ០០ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០១នាក់ | ២១ | ខេត្ត រតនគិរី | ០១ នាក់ | |
| | | | ២២ | ក្រុងកែប | ០១ នាក់ | |
| | | សរុប : | | | **៥៤ នាក់** | |